ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

១.ព្រះរាជក្រម

២០-៧-២០០៧ -ព្រះរាជក្រម នស/រកម/០៧០៧/០១៩ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ៥៦៤១

២០-៧-២០០៧ -ព្រះរាជក្រម នស/រកម/០៧០៧/០២០ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ ៥៦៨៦

២.ព្រះរាជក្រឹត្យ

២០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៩៨ ស្តីពីការតម្លើងឋានៈស្មើ អនុរដ្ឋលេខាធិការ ជូនឯកឧត្តម ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាចំនួន ០២ រូប ៥៦៨៩

២០-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៩៩ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឧត្តមសេនីយ៍ទោ **អ៊ុក ឡឿន** ៥៦៩០

២៣-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣០០ ស្តីពីការផ្ទេរក្របខ័ណ្ឌ លោក **ឈឹម សុផាណាវ៉ាត** ពីអនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអភិវឌ្ឍន៍ជនបទ ទៅបម្រើការងារជាអនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៥៦៩១

២៣-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣០១ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីចំនួន ០៣ រូបនៃក្រសួងយុត្តិធម៌ ៥៦៩២

២៣-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣០២ ស្តីពីការតែងតាំងទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ចំនួន ០២ រូប ៥៦៩៣

២៣-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/៣០៣ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោកស្រីឧត្តមសេនីយ៍ត្រី **អ៊ុន សុគន្ធា** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៥៦៩៤

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

២៤-៧-២០០៧	-អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមជូនក្រសួង-ស្ថាប័ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧	៥៦៩៥
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៥៦៩៧
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានសង្គមសាស្ត្រ និង បច្ចេកវិទ្យា	៥៦៩៩
២៤-៧-២០០៧	-អនុក្រឹត្យលេខ ៨៣ អនក្រ បក ស្តីពីការបង្កើតពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា	៥៧០២
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៨៤ អនក្រ បក ស្តីពីការរំសាយក្រុមហ៊ុនជលផលជាសហគ្រាស សាធារណៈ និងក្រុមប្រឹក្សាភិបាល	៥៧០៥
២៥-៧-២០០៧	-អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៥៧០៧
២៦-៧-២០០៧	-អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៥៧០៩
១៨-៧-២០០៧	-អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីក្រមការ តាម លក្ខន្តិកៈដោយឡែក	៥៧១១
១៨-៧-២០០៧	-អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៧៣២
១៨-៧-២០០៧	-អនុក្រឹត្យលេខ ៥៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៧៣៣
១៨-៧-២០០៧	-អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៧៣៥
១៨-៧-២០០៧	-អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៧៣៧
១៨-៧-២០០៧	-អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ	៥៧៣៩
១៩-៧-២០០៧	-អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ	៥៧៤០
១៩-៧-២០០៧	-អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៥៧៤២
១៩-៧-២០០៧	-អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៥៧៤៤
១៩-៧-២០០៧	-អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៥៧៤៥
២០-៧-២០០៧	-អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៥៧៤៦

២០-៧-២០០៧ -អនុក្រឹត្យលេខ ៩៧១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៧៤៧
២០-៧-២០០៧ -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម ៥៧៤៩
២៣-៧-២០០៧ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្តីពីការតាំងស៊ប់មន្ត្រីរាជការ ៥៧៥១
២៣-៧-២០០៧ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧៥២

III. ការងារបណ្តាក្រសួង

១. លិខិតបទដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១. ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៩ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ *(ត មកពីរាជកិច្ច លេខ ៤៩,៥០,៥១,៥២,៥៣,៥៤,៥៥)* ៥៧៥៣

២. សារាចរណែនាំ

១២-៧-២០០៧ -សារាចរណែនាំលេខ ០០១ សហវ ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា ខេត្ត ក្រុង ឆ្នាំ ២០០៨ ៥៧៧៦

២. លិខិតបទដ្ឋានរបស់ក្រសួងយុត្តិធម៌

សារាចរណែនាំ

០៣-៧-២០០៧ -សារាចរណែនាំលេខ ០១ កយ.សរណន/០៧ ស្តីពីចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្តីដែលមានពាក់ព័ន្ធនឹងដីរដ្ឋ ៥៧៩៤

ព្រះរាជក្រម

នស/រកម/០៧០៧/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការការពារនិងការលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារ និង ការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌

មាត្រា ១.–

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដែលអនុម័តកាលពីថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥ នៅទីក្រុងប៉ារីស ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.–

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស.០៧០៧.៣១២

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា

ហ៊ឹម ឆែម

លេខ: ៣០៥ ធ.ល
បានឃើញ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

អនុសញ្ញា ស្ដីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

ទីក្រុងប៉ារីស ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥

អនុសញ្ញាស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

អនុសញ្ញាស្តីពីការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

សន្និសីទទូទៅ នៃអង្គការយូណេស្កូ ដែលបានធ្វើឡើងនៅទីក្រុងប៉ារីស ពីថ្ងៃទី០៣ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ សម្រាប់សម័យប្រជុំលើកទី៣៣របស់ខ្លួន

ដោយអះអាងថា ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាចរិតលក្ខណៈមួយមានពីកំណើតរបស់មនុស្សជាតិ

ដោយយល់ឃើញថា ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាបេតិកភណ្ឌរួមរបស់មនុស្សជាតិ និងគួរតែត្រូវបានលើកតម្កើង និងថែរក្សា ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិទាំងអស់

ដោយដឹងថា ភាពផ្សេងៗគ្នានៃវប្បធម៌បង្កើតបានពិភពមួយពោរពេញទៅដោយភាពសំបូរបែប និងភាពប្លែកៗគ្នាដែលពង្រីកនូវលទ្ធភាពជម្រើសបានច្រើន បណ្តុះនូវសមត្ថភាព និងតម្លៃមនុស្ស ហើយភាពផ្សេងៗគ្នានៃវប្បធម៌គឺជាកំលាំងគ្រឹះនៃការអភិវឌ្ឍប្រកបដោយចីរភាពនៃសហគមន៍ ប្រជាជន និងប្រជាជាតិ

ដោយរំលឹកឡើងវិញថា ភាពផ្សេងៗគ្នានៃវប្បធម៌ដែលរីកលូតលាស់នៅក្នុងក្របខ័ណ្ឌនៃលទ្ធិប្រជាធិបតេយ្យ ភាពសណ្តោសអត់ឱន យុត្តិធម៌សង្គម និងការគោរពគ្នាទៅវិញទៅមករវាងប្រជាជន និង ប្រជាជន រវាងវប្បធម៌ និងវប្បធម៌ គឺជាកត្តាចាំបាច់ខានមិនបានដល់សន្តិភាព និង សន្តិសុខក្នុងតំបន់ ជាតិ និងអន្តរជាតិ

ដោយលើកតម្កើង សារៈសំខាន់នៃភាពផ្សេងៗគ្នានៃវប្បធម៌ដើម្បីធ្វើឱ្យសម្រេចបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានប្រកាសនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ក៏ដូចជានៅក្នុងលិខិតូបករណ៍ផ្សេងទៀតដែលត្រូវបានទទួលស្គាល់ជាសាកល

ដោយគូសបញ្ជាក់ ពីភាពចាំបាច់ក្នុងការធ្វើសមាហរណកម្មវប្បធម៌ជាធាតុផ្សំយុទ្ធសាស្ត្រទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំងទៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍន៍ ដោយចាប់អារម្មណ៍ផងដែរទៅលើសេចក្តីថ្លែងការណ៍សហសវត្សរបស់អង្គការសហប្រជាជាតិ(ឆ្នាំ២០០០) ដែលផ្តោតលើការលុបបំបាត់ភាពក្រីក្រ

ដោយសង្កេតឃើញថា វប្បធម៌មានទម្រង់ប្លែកៗគ្នាទៅតាមកាលវេលា និងទីកន្លែង ហើយ *ដោយសង្កេតឃើញថា* ភាពប្លែកៗគ្នានេះចាប់បដិសន្ធិឡើងនៅក្នុងភាពថ្មីប្លែកពីគេ និងក្នុងពហុភាព

នៃអត្តសញ្ញាណ ព្រមទាំងនៅក្នុងវិញ្ញត្តិវប្បធម៌របស់ប្រជាជន និងសង្គមដែលរួមផ្សំ បង្កើតជាមនុស្សជាតិ

ដោយទទួលស្គាល់ សារៈសំខាន់នៃចំណេះដឹងជាប្រពៃណី ជាប្រភពនៃធនធានអរូបី និងរូបី និងជាពិសេសសារៈសំខាន់នៃប្រព័ន្ធចំណេះដឹងរបស់ប្រជាជនម្ចាស់ស្រុក ហើយដោយទទួលស្គាល់នូវការរួមចំណែកជាវិជ្ជមាននៃចំណេះដឹងទាំងនេះដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងភាពចាំបាច់ក្នុងការការពារ និងលើកស្ទួយចំណេះដឹងទាំងនេះឱ្យបានសមស្រប

ដោយទទួលស្គាល់ ភាពចាំបាច់ក្នុងការចាត់វិធានការដើម្បីការពារភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ រួមទាំងខ្លឹមសារចម្រុះរបស់វាផងដែរ ជាពិសេសនៅក្នុងស្ថានភាពដែលភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌អាចទទួលរងនូវការគំរាមកំហែងផុតរលត់ ឬការខូចខាតធ្ងន់ធ្ងរ

ដោយកត់សំគាល់ឃើញពី សារៈសំខាន់របស់វប្បធម៌ក្នុងការធ្វើឱ្យមានសាមគ្គីភាពក្នុងសង្គមជាទូទៅ និងជាពិសេសការចូលរួមចំណែករបស់វប្បធម៌ក្នុងការលើកស្ទួយឋានៈ និងតួនាទីរបស់ស្ត្រីនៅក្នុងសង្គម

ដោយយល់ឃើញថា ភាពផ្សេងៗគ្នានៃវប្បធម៌ត្រូវបានពង្រឹងដោយការផ្លាស់ប្តូរគំនិតគ្នាដោយសេរី និងដោយយល់ឃើញថា ភាពផ្សេងៗគ្នានៃវប្បធម៌ធ្វើឱ្យមានការផ្លាស់ប្តូរជាច្រើនព្រមទាំងធ្វើឱ្យមានអន្តរកម្ម រវាងវប្បធម៌ និងវប្បធម៌

ដោយបញ្ជាក់ឡើងវិញថា សេរីភាពនៃការគិត ការបញ្ចេញមតិ និងការទទួលបានព័ត៌មាន ព្រមទាំងពហុប្រព័ន្ធផ្សព្វផ្សាយអាចធ្វើឱ្យមានការរីកលូតលាស់ដល់វិញ្ញត្តិវប្បធម៌នៅក្នុងសង្គមនីមួយៗ

ដោយទទួលស្គាល់ថា ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ រួមទាំងវិញ្ញត្តិវប្បធម៌ជាលក្ខណៈប្រពៃណីនានា គឺជាកត្តាដ៏សំខាន់ដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ៗ និងប្រជាជនធ្វើការបកស្រាយ បង្ហាញ និង ចែករំលែកគំនិត ព្រមទាំងតម្លៃរបស់ខ្លួនជាមួយអ្នកដទៃ

ដោយរំលឹកឡើងវិញថា ភាពផ្សេងៗគ្នានៃភាសា គឺជាធាតុផ្សំគ្រឹះមួយនៃភាពផ្សេងៗគ្នានៃវប្បធម៌ និង *ដោយបញ្ជាក់ឡើងវិញ*ពីតួនាទីជាមូលដ្ឋាននៃការអប់រំនៅក្នុងការការពារ និងការលើកស្ទួយនូវវិញ្ញត្តិវប្បធម៌នានា

ដោយសង្កេតឃើញពី សារៈសំខាន់នៃភាពរៀវក្លារបស់វប្បធម៌សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងសម្រាប់មនុស្សក្នុងក្រុមជនជាតិភាគតិច និងសម្រាប់ប្រជាជនម្ចាស់ស្រុក ដូចដែលវាស្តែងឡើងតាមរយៈសេរីភាពរបស់ពួកគេក្នុងការបង្កើត ផ្សព្វផ្សាយ និងចែកចាយនូវ វិញ្ញត្តិវប្បធម៌ជាលក្ខណៈប្រពៃណីរបស់ពួកគេ និងចូលរួមដើម្បីជួយសម្រួលដល់ការអភិវឌ្ឍន៍របស់ខ្លួនគេផ្ទាល់

ដោយកត់សំគាល់ឃើញ ពីតួនាទីដ៏សំខាន់នៃអន្តរកម្ម និងគំនិតច្នៃប្រឌិតផ្នែកវប្បធម៌ដែលបណ្តុះ និងបង្កើតថ្មីឡើងវិញនូវវិញ្ញត្តិវប្បធម៌ ព្រមទាំងពង្រឹងតួនាទីរបស់បុគ្គលដែលធ្វើការដើម្បីអភិវឌ្ឍវប្បធម៌ សំដៅឈានទៅរកវឌ្ឍនភាពក្នុងសង្គមទាំងមូល

ដោយទទួលស្គាល់ពី សារៈសំខាន់នៃសិទ្ធិលើកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់បុគ្គលទាំងឡាយដែលចូលរួមក្នុងការច្នៃប្រឌិតបង្កើតថ្មីផ្នែកវប្បធម៌

ដោយជឿជាក់ថា សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌មានធម្មជាតិពីរ គឺសេដ្ឋកិច្ច និងវប្បធម៌ ព្រោះវាបង្កប់ទៅដោយអត្តសញ្ញាណ តម្លៃ និងអត្ថន័យ ហើយអាស្រ័យហេតុនេះ សកម្មភាពទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទាំងនេះមិនត្រូវចាត់ទុកថាមានតម្លៃត្រឹមតែខាងពាណិជ្ជកម្មតែមួយមុខឡើយ

ដោយសង្កេតឃើញថា ចរន្តសាកលភាវូបនីយកម្ម ដែលត្រូវបានសម្រួលដោយការវិវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ប្រសិនបើវាបង្កើតជាល័ក្ខខ័ណ្ឌថ្មីនៃអន្តរកម្មដែលត្រូវបានពង្រឹងរវាងវប្បធម៌និងវប្បធម៌ ចរន្តនេះបង្កជាបញ្ហាប្រឈមសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ ជាពិសេសហានិភ័យនៃអតុល្យភាពរវាងប្រទេសអ្នកមាន និងប្រទេសអ្នកក្រ

ដោយឈ្វេងយល់ពី អាណត្តិពិសេសដែលប្រគល់ដល់អង្គការយូណេស្កូ ក្នុងការធានាឱ្យមានការគោរពភាពផ្សេងៗគ្នានៃវប្បធម៌ និងផ្តល់អនុសាសន៍ឱ្យមានកិច្ចព្រមព្រៀងអន្តរជាតិដែលអង្គការយល់ថាមានសារៈប្រយោជន៍ដើម្បីសម្រួលឱ្យមានការផ្លាស់ប្តូរគំនិតគ្នាដោយសេរីតាមរយៈពាក្យសំដី និងរូបភាព

ដោយយោងលើ បទប្បញ្ញត្តិនៃលិខិតូបករណ៍អន្តរជាតិនានាដែលអនុម័តដោយអង្គការយូណេស្កូ ពាក់ព័ន្ធនឹងភាពផ្សេងៗគ្នានៃវប្បធម៌និងការអនុវត្តន៍សិទ្ធិផ្នែកវប្បធម៌ និងជាពិសេសដោយយោងលើសេចក្តីថ្លែងការណ៍ជាសាកលស្តីពីភាពផ្សេងៗគ្នានៃវប្បធម៌ ឆ្នាំ២០០១ សន្និសីទកំពូលលើកទី ៣៣ របស់អង្គការសហប្រជាជាតិដើម្បីការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងប៉ារីស ពីថ្ងៃទី០៣ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ *បានអនុម័ត*អនុសញ្ញានេះនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ :

ជំពូកទី ១
គោលដៅ និង គោលការណ៍តម្រង់ទិស

មាត្រា ១.- គោលដៅ

អនុសញ្ញានេះមានគោលដៅ :

(ក) ការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវប្បធម៌

(ខ) បង្កើតជាល័ក្ខខ័ណ្ឌដែលអាចឱ្យវប្បធម៌រីកលូតលាស់ និងមានអន្តរកម្មដោយសេរី សំដៅធ្វើឱ្យវប្បធម៌ទាំងអស់មានលក្ខណៈសំបូរបែបទៅវិញទៅមក

(គ) លើកទឹកចិត្តឱ្យមានទំនាក់ទំនងរវាងវប្បធម៌ និងវប្បធម៌ ដើម្បីធានាឱ្យមានការផ្លាស់ប្តូរវប្បធម៌គ្នាឱ្យកាន់តែខ្លាំងក្លាឡើង និងមានតុល្យភាពនៅក្នុងពិភពលោក សំដៅឱ្យមានការគោរពអន្តរវប្បធម៌ និងវប្បធម៌សន្តិភាព

(ឃ) ជំរុញអន្តរភាពវប្បធម៌ដើម្បីអភិវឌ្ឍអន្តរកម្មវប្បធម៌ នៅក្នុងស្មារតីកសាងស្ពានទំនាក់ទំនងរវាងប្រជាជន និងប្រជាជន

(ង) លើកកំពស់ការគោរពភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ និងការយល់ដឹងពីតម្លៃរបស់វា ក្នុងកំរិតតំបន់ ជាតិ និងអន្តរជាតិ

(ច) ធ្វើការបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃចំណងទាក់ទងរវាងវប្បធម៌ និងការអភិវឌ្ឍន៍សម្រាប់គ្រប់ប្រទេសទាំងអស់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍ និងជំរុញរាល់សកម្មភាពដែលធ្វើឡើងនៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីធ្វើឱ្យតម្លៃដ៏ពិតប្រាកដនៃចំណងទាក់ទងនេះត្រូវបានទទួលស្គាល់

(ឆ) ទទួលស្គាល់ធម្មជាតិពិសេសនៃសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ជាវត្ថុរក្សាអត្តសញ្ញាណ តម្លៃ និងអត្ថន័យ

(ជ) ធ្វើការបញ្ជាក់ឡើងវិញពីសិទ្ធិអធិបតេយ្យរបស់រដ្ឋនានាក្នុងការអភិរក្ស អនុម័ត និងអនុវត្តគោលនយោបាយ និងវិធានការដែលខ្លួនយល់ថាសមស្របសម្រាប់ការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌នៅលើទឹកដីនៃរដ្ឋទាំងនោះ

(ឈ) ពង្រឹងកិច្ចសហប្រតិបត្តិការ និងចំណងសាមគ្គីភាពជាអន្តរជាតិ នៅក្នុងស្មារតីភាពជាដៃគូដើម្បីបង្កើនសមត្ថភាពរបស់ប្រទេសកំពុងអភិវឌ្ឍក្នុងការការពារ និងលើកលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌

មាត្រា ២ .- គោលការណ៍តម្រង់ទិស

១- គោលការណ៍គោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

ភាពផ្សេងៗគ្នានៃវប្បធម៌អាចត្រូវបានការពារ និងលើកស្ទួយ លុះត្រាតែសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចជាសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងប្រាស្រ័យទាក់ទង ក៏ដូចជាលទ្ធភាពរបស់បុគ្គលគ្រប់រូបក្នុងការជ្រើសរើសវិញ្ញត្តិវប្បធម៌ ត្រូវបានធានា។ គ្មានបុគ្គលណាម្នាក់អាចលើកពីបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដើម្បីធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ឬ ធានាដោយនីតិអន្តរជាតិ ឬដើម្បីដាក់កំរិតអានុភាពនៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានបានឡើយ។

២- គោលការណ៍អធិបតេយ្យភាព

អនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងគោលការណ៍នៃនីតិអន្តរជាតិ រដ្ឋនីមួយៗមានសិទ្ធិអធិបតេយ្យក្នុងការអនុម័តរាល់វិធានការនិងគោលនយោបាយ ដើម្បីការពារនិងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌នៅលើទឹកដីនៃរដ្ឋនោះ ។

៣-គោលការណ៍នៃសេចក្តីថ្លៃថ្នូរដោយស្មើភាពគ្នា និងគោលការណ៍គោរពវប្បធម៌ទាំងអស់

ការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌តម្រូវឱ្យមានការទទួលស្គាល់សេចក្តីថ្លៃថ្នូរដោយស្មើភាពគ្នា និងការគោរពវប្បធម៌ទាំងអស់ រួមទាំងវប្បធម៌របស់ក្រុមជនជាតិភាគតិច និងវប្បធម៌របស់ប្រជាជនម្ចាស់ស្រុកផងដែរ ។

៤- គោលការណ៍សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពអន្តរជាតិគប្បីអនុញ្ញាតឱ្យប្រទេសទាំងអស់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍអាចបង្កើត និងពង្រឹងមធ្យោបាយចាំបាច់ដល់វិញ្ញត្តិវប្បធម៌របស់ពួកគេ រួមទាំងឧស្សាហកម្មវប្បធម៌របស់ពួកគេ ទោះជាកើតឡើងដោយឯកឯង ឬត្រូវបានបង្កើតឡើងក្នុងកម្រិតតំបន់ ជាតិ និងអន្តរជាតិក៏ដោយ ។

៥- គោលការណ៍បំពេញបន្ថែមរវាងទិដ្ឋភាពសេដ្ឋកិច្ច និងទិដ្ឋភាពវប្បធម៌នៃការអភិវឌ្ឍ

ដោយសារវប្បធម៌ គឺជាកំលាំងគ្រឹះនៃការអភិវឌ្ឍ ទិដ្ឋភាពវប្បធម៌នៃការអភិវឌ្ឍក៏មានសារៈសំខាន់ដូចទិដ្ឋភាពសេដ្ឋកិច្ចដែរ ហើយបុគ្គលគ្រប់រូប និងប្រជាជនមានសិទ្ធិជាមូលដ្ឋានក្នុងការចូលរួម ឬទាញយកអត្ថប្រយោជន៍ពីវា ។

៦- គោលការណ៍អភិវឌ្ឍប្រកបដោយនិរន្តរភាព

ភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាធនធានដ៏ធំមួយសម្រាប់មនុស្សគ្រប់រូប និងសង្គមជាតិ ។ ការការពារ ការលើកស្ទួយ និងការថែរក្សាភាពផ្សេងៗគ្នានៃវប្បធម៌ គឺជាលក្ខខណ្ឌមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពជាប្រយោជន៍ដល់មនុស្សជំនាន់នេះ និងជំនាន់ក្រោយ ។

៧- គោលការណ៍នៃសិទ្ធិទទួលបានប្រកបដោយសមធម៌

សិទ្ធិនៃការទទួលបានប្រកបដោយសមធម៌នូវបណ្តុំដ៏សំបូរបែប និងចម្រុះគ្នានៃវិញ្ញត្តិវប្បធម៌ដែលមានប្រភពមកពីពិភពលោកទាំងមូល ព្រមទាំងសិទ្ធិនៃការទទួលបានវប្បធម៌ តាមរយៈមធ្យោបាយនៃវិញ្ញត្តិ និងការផ្សព្វផ្សាយ គឺជាធាតុដ៏សំខាន់ ដើម្បីលើកតម្លៃភាពផ្សេងៗគ្នានៃវប្បធម៌ និងជំរុញឱ្យមានការយោគយល់គ្នាទៅវិញទៅមក។

៨- គោលការណ៍បើកចំហ និងតុល្យភាព

នៅពេលរដ្ឋទាំងអស់អនុម័តទទួលយកវិធានការ សំដៅបង្កលក្ខណៈអនុគ្រោះដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ បណ្តារដ្ឋទាំងអស់គប្បីយកចិត្តទុកដាក់ក្នុងការលើកកម្ពស់នៃការបើកចំហ

ផល់វប្បធម៌ដទៃទៀតរបស់ពិភពលោកឱ្យបានសមស្រប និងធានាថាវិធានការទាំងនេះមានភាពត្រឹមត្រូវ ស្របតាមគោលដៅដែលអនុសញ្ញានេះចង់បាន ។

ជំពូកទី ២
វិសាលភាពអនុវត្តន៍

មាត្រា ៣.- **វិសាលភាពអនុវត្តន៍**

អនុសញ្ញានេះអនុវត្តន៍ចំពោះគោលនយោបាយ និងវិធានការដែលអនុម័តដោយរដ្ឋភាគីពាក់ព័ន្ធនឹងការការពារ និងការលើកស្ទួយភាពចម្រុះនៃវិញ្ញត្តិវប្បធម៌ ។

ជំពូកទី ៣
និយមន័យ

មាត្រា ៤.- ***និយមន័យ***

ដើម្បីបម្រើគោលដៅនៃអនុសញ្ញានេះ ពាក្យដែលប្រើប្រាស់មួយចំនួនមានអត្ថន័យដូចតទៅ:

១- **ភាពចម្រុះនៃវប្បធម៌**

ពាក្យថា "*ភាពចម្រុះនៃវប្បធម៌*" សំដៅដល់ពហុភាពនៃទម្រង់ ដែលតាមរយៈនោះវប្បធម៌របស់ក្រុមមនុស្ស និងសង្គមអាចស្វែងរកឃើញនូវវិញ្ញត្តិរបស់ខ្លួន ។ វិញ្ញត្តិទាំងនេះនឹងផ្ទេរបន្តទៅឱ្យគ្នាទៅវិញទៅមកក្នុងចំណោមក្រុមមនុស្ស និងសង្គម ហើយរវាងសង្គម និងសង្គម ។

ភាពចម្រុះនៃវប្បធម៌មិនត្រឹមតែស្តែងឡើងនៅក្នុងទម្រង់ប្លែកៗគ្នា ដែលតាមរយៈនោះបេតិកភណ្ឌវប្បធម៌របស់មនុស្សជាតិត្រូវបានសំដែងចេញ ត្រូវបានធ្វើឱ្យកាន់តែមានភាពសំបូរបែប និងត្រូវបានផ្ទេរអាស្រ័យដោយសារមានភាពខុសគ្នានៃវិញ្ញត្តិវប្បធម៌ប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈវិធីផ្សេងៗក្នុងការបង្កើតស្នាដៃសិល្បៈ ការផលិត ការផ្សព្វផ្សាយ ការចែកចាយ និងការអាស្រ័យផលពីវិញ្ញត្តិវប្បធម៌នានា ទោះបីជាប្រើប្រាស់មធ្យោបាយ និងបច្ចេកវិទ្យាបែបណាក៏ដោយ ។

២- **ខ្លឹមសារវប្បធម៌**

ពាក្យថា "*ខ្លឹមសារវប្បធម៌*" សំដៅដល់អត្ថន័យជានិមិត្តរូបដល់ទំហំនៃសិល្បៈ និងដល់តម្លៃនៃវប្បធម៌ ដែលមានប្រភពដើម ឬបង្ហាញពីអត្តសញ្ញាណវប្បធម៌ ។

៣- **វិញ្ញត្តិវប្បធម៌**

ពាក្យថា "*វិញ្ញត្តិវប្បធម៌*" សំដៅដល់វិញ្ញត្តិដែលកើតចេញពីគំនិតច្នៃប្រឌិតរបស់បុគ្គលម្នាក់ៗ របស់ក្រុមមនុស្ស និងសង្គម ហើយមានបង្កប់នូវខ្លឹមសារវប្បធម៌ ។

៤- សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌

ពាក្យថា "សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌" សំដៅដល់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្ម ដែលនិមិត្តតំណាង ឬផ្ទេរនូវវិញ្ញត្តិវប្បធម៌នានា ដោយមិនអាស្រ័យនឹងតម្លៃខាងពាណិជ្ជកម្មដែលអាចមានឡើយ ចាប់ពីពេលដែលសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មទាំងនេះត្រូវបានយកចិត្តទុកដាក់ខាងផ្នែកគុណភាព បម្រើបម្រាស់ ឬគោលដៅពិសេសរបស់វា ។ សកម្មភាពវប្បធម៌អាចមិនបញ្ចប់ត្រឹមនេះទេ ឬអាចរួមចំណែកក្នុងការផលិតទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទៀតផង ។

៥- ឧស្សាហកម្មវប្បធម៌

ពាក្យ "ឧស្សាហកម្មវប្បធម៌" សំដៅដល់ឧស្សាហកម្មដែលផលិត និងចែកចាយទ្រព្យសម្បត្តិ ឬសេវាកម្មវប្បធម៌ ដូចដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី៤ខាងលើ ។

៦- គោលនយោបាយ និងវិធានការវប្បធម៌

ពាក្យថា "គោលនយោបាយ និងវិធានការវប្បធម៌" សំដៅដល់គោលនយោបាយ និងវិធានការ ដែលពាក់ព័ន្ធនឹងវប្បធម៌ក្នុងកម្រិតមូលដ្ឋាន ជាតិ តំបន់ ឬអន្តរជាតិ ទោះជាគោលនយោបាយ និងវិធានការទាំងនេះផ្តោតលើវប្បធម៌ ឬប្រើសម្រាប់ជះឥទ្ធិពលដោយផ្ទាល់ទៅលើវិញ្ញត្តិវប្បធម៌របស់បុគ្គលម្នាក់ៗ ក្រុមមនុស្ស ឬសង្គម រួមទាំងទៅលើការបង្កើត ការផលិត ការផ្សព្វផ្សាយ និងការចែកចាយសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ និងលើការទទួលបានផលពីអ្វីៗទាំងនេះក៏ដោយ ។

៧- ការការពារ

ពាក្យថា "ការការពារ" មានន័យថាការអនុម័តយល់ព្រមទទួលយកវិធានការដែលសំដៅធ្វើការអភិរក្ស ការថែរក្សា និងការលើកតម្លៃភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

"ការពារ" មានន័យថាអនុម័តយល់ព្រមទទួលយកវិធានការទាំងនោះ ។

៨- អន្តរវប្បធម៌ភាព

"អន្តរវប្បធម៌ភាព" សំដៅដល់អត្ថិភាព និងអន្តរកម្មប្រកបដោយសមធម៌នៃវប្បធម៌ផ្សេងៗ ព្រមទាំងលទ្ធភាពបង្កើតឱ្យមានជាវិញ្ញត្តិវប្បធម៌ដែលចែករំលែកដោយទំនាក់ទំនងគ្នា និងការគោរពគ្នាទៅវិញទៅមក ។

ជំពូកទី ៤

សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគី

មាត្រា ៥.- វិធានទូទៅពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ច

១- ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ គោលការណ៍នៃនីតិអន្តរជាតិ និងលិខិតូបករណ៍ ដែលត្រូវបានទទួលស្គាល់ជាសាកលក្នុងវិស័យសិទ្ធិមនុស្ស រដ្ឋភាគីទាំងអស់

បញ្ជាក់អះអាងជាថ្មីថា សិទ្ធិអធិបតេយ្យក្នុងការរៀបចំតាក់តែង និងការអនុវត្តនូវគោលនយោបាយវប្បធម៌របស់ខ្លួន និងអនុម័តទទួលយកវិធានការដើម្បីការពារ និងលើកស្ទួយភាពចម្រុះនៃវិញ្ញត្តិវប្បធម៌ ព្រមទាំងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅឈានទៅសម្រេចឱ្យបាននូវគោលដៅនៃអនុសញ្ញានេះ ។

២- នៅពេលដែលរដ្ឋភាគីណាមួយអនុវត្តគោលនយោបាយ និងចាត់វិធានការដើម្បីការពារ និងលើកស្ទួយភាពចម្រុះនៃវិញ្ញត្តិវប្បធម៌ នៅលើដែនដីរបស់ខ្លួន ពេលនោះគោលនយោបាយ និងវិធានការរបស់រដ្ឋភាគីនោះត្រូវតែស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។

មាត្រា ៦.- សិទ្ធិរបស់រដ្ឋភាគីទាំងអស់នៅថ្នាក់ជាតិ

១- នៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយ និងវិធានការវប្បធម៌ ដូចដែលបានរៀបរាប់នៅក្នុងមាត្រា៤.៦និងដោយយោងទៅលើកាលៈទេសៈ ព្រមទាំងតម្រូវការរបស់ខ្លួនផ្ទាល់ រដ្ឋភាគីនីមួយៗអាចអនុម័តទទួលយកវិធានការសម្រាប់ការពារ និងលើកស្ទួយភាពចម្រុះនៃវិញ្ញត្តិវប្បធម៌ នៅលើដែនដីរបស់ខ្លួន ។

២- វិធានការនេះអាចរួមបញ្ចូល :

(ក) រាល់វិធានការជាបទបញ្ញាដែលមានគោលដៅការពារ និងលើកស្ទួយភាពចម្រុះនៃវិញ្ញត្តិវប្បធម៌

(ខ) រាល់វិធានការដែលផ្តល់កាលានុវត្តភាពយ៉ាងសមស្របដល់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ជាតិឱ្យមានវត្តមានក្នុងចំណោមសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទាំងអស់ ដែលមាននៅក្នុងដែនដីរបស់ខ្លួនពាក់ព័ន្ធនឹងការបង្កើត ការផលិត ការផ្សព្វផ្សាយ ការចែកចាយ និងការអាស្រ័យផលរួមទាំងវិធានការពាក់ព័ន្ធនឹងភាសាប្រើប្រាស់សម្រាប់សកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មទាំងអស់ខាងលើនេះ

(គ) រាល់វិធានការដែលមានគោលដៅផ្តល់ដល់ឧស្សាហកម្មវប្បធម៌ជាតិឯករាជ្យ និងដល់សកម្មភាពនៃវិស័យក្រៅផ្លូវការនូវការទទួលផលបានពិតប្រាកដ នៃមធ្យោបាយផលិតកម្ម ការផ្សព្វផ្សាយ និងការចែកចាយសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌

(ឃ) រាល់វិធានការដែលមានគោលដៅផ្តល់ជំនួយហិរញ្ញវត្ថុសាធារណៈ

(ង) រាល់វិធានការដែលមានគោលដៅជំរុញបណ្តាអង្គការដែលគ្មានគោលបំណងស្វែងរកផលចំណេញ ព្រមទាំងស្ថាប័នសាធារណៈ និងស្ថាប័នឯកជន សិល្បករ និងអ្នកវិជ្ជាជីវៈខាងវប្បធម៌ដទៃទៀតឱ្យចូលរួមអភិវឌ្ឍ និងលើកស្ទួយការប្តូរដោយសេរី និងការផ្លាស់ប្តូរគំនិតដោយសេរី និងវិញ្ញត្តិវប្បធម៌ ព្រមទាំងសកម្មភាព ទ្រព្យសម្បត្តិ

និងសេវាកម្មវប្បធម៌ និងជំរុញឱ្យមានការបង្កើត និងមានគំនិតផ្តួចផ្តើម នៅក្នុងសកម្មភាពរបស់ខ្លួន

(ង) រាល់វិធានការដែលមានគោលដៅបង្កើត និងគាំទ្រយ៉ាងសមស្របដល់បណ្តាស្ថាប័នផ្តល់សេវាសាធារណៈ

(ឆ) រាល់វិធានការដែលមានគោលដៅជំរុញ និងគាំទ្រសិល្បករព្រមទាំងបុគ្គលដែលចូលរួមនៅក្នុងការបង្កើតឡើងនូវវិញ្ញត្តិវប្បធម៌

(ជ) រាល់វិធានការដែលមានគោលដៅលើកស្ទួយពហុប្រព័ន្ធផ្សព្វផ្សាយ រួមទាំងតាមរយៈសេវាសាធារណៈ ផ្នែកវិទ្យុផ្សព្វផ្សាយ ។

មាត្រា ៧.- វិធានការសម្រាប់លើកស្ទួយវិញ្ញត្តិវប្បធម៌

១- រដ្ឋភាគីទាំងអស់ព្យាយាមបង្កើតនៅលើទឹកដីរបស់ខ្លួននូវបរិស្ថានមួយដែលលើកទឹកចិត្តដល់បុគ្គលគ្រប់រូប និងក្រុមសង្គមមនុស្សឱ្យ :

(ក) បង្កើត ផលិត ផ្សព្វផ្សាយ និងចែកចាយវិញ្ញត្តិវប្បធម៌ផ្ទាល់របស់ខ្លួន និងបានចូលរួម ក្នុងនោះដោយផ្តោតការយកចិត្តទុកដាក់ដល់លក្ខខ័ណ្ឌ និងតម្រូវការពិសេសរបស់ស្ត្រី ព្រមទាំងក្រុមសង្គមមនុស្សផ្សេងៗទៀត រួមទាំងក្រុមជនជាតិភាគតិច និងប្រជាជនម្ចាស់ស្រុក ។

(ខ) បានចូលរួមក្នុងរាល់វិញ្ញត្តិវប្បធម៌ផ្សេងៗ ដែលមានប្រភពដើមនៅក្នុងដែនដីរបស់ខ្លួន ក៏ដូចជាក្នុងប្រទេសដទៃទៀតនៅលើពិភពលោក ។

២- រដ្ឋភាគីទាំងអស់ក៏ព្យាយាមផងដែរ ក្នុងការទទួលស្គាល់ការរួមចំណែកដ៏សំខាន់របស់សិល្បករ និងបុគ្គលគ្រប់រូប ដែលបានចូលរួមនៅក្នុងដំណើរនៃការច្នៃប្រឌិតបង្កើតថ្មីរបស់បណ្តាសហគមន៍វប្បធម៌ និងបណ្តាអង្គការដែលគាំទ្រដល់សហគមន៍វប្បធម៌ទាំងនោះ នៅក្នុងការងាររបស់ពួកគេ ព្រមទាំងតួនាទីស្នូលរបស់ពួកគេក្នុងការបណ្តុះនូវភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

មាត្រា ៨.- វិធានការសម្រាប់ការពារវិញ្ញត្តិវប្បធម៌

១- រដ្ឋភាគីមួយអាចវិភាគវិនិច្ឆ័យពីអត្ថិភាពនៃស្ថានភាពពិសេស ដែលវិញ្ញត្តិវប្បធម៌នៅលើដែនដីរបស់ខ្លួន មានការប្រឈមចំពោះគ្រោះនៃការផុតរលត់ ការគំរាមកំហែងធ្ងន់ធ្ងរ ឬទាមទារឱ្យមានការអភិរក្សជាបន្ទាន់ ទោះជាតាមរបៀបណាក៏ដោយ ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃមាត្រា ៥ និងមាត្រា ៦ ។

២- រដ្ឋភាគីទាំងអស់អាចចាត់វិធានការសមស្របគ្រប់បែបយ៉ាង ដើម្បីការពារ និងថែរក្សាវិញ្ញត្តិវប្បធម៌ នៅក្នុងស្ថានភាពដែលមានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី ១ ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ។

៣- រដ្ឋភាគីទាំងអស់ធ្វើរបាយការណ៍ជូនគណៈកម្មាធិការអន្តររដ្ឋាភិបាល ដូចមានចែងនៅក្នុងមាត្រា២៣ ស្តីពីវិធានការទាំងអស់ដែលត្រូវបានអនុវត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃស្ថានភាព ហើយគណៈកម្មាធិការអាចផ្តល់ជាអនុសាសន៍សមស្រប ។

មាត្រា ៩.- ការចែករំលែកព័ត៌មាន និងតម្លាភាព

រដ្ឋភាគីទាំងអស់ ៖

(ក) ផ្តល់រៀងរាល់បួនឆ្នាំម្តង នៅក្នុងរបាយការណ៍ជូនអង្គការយូណេស្កូ នូវព័ត៌មានសមស្របស្តីពីវិធានការដែលត្រូវបានអនុវត្ត ដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិប្បធម៌ នៅលើដែនដីរបស់ខ្លួន និងនៅលើឆាកអន្តរជាតិ

(ខ) ចាត់តាំងផ្នែកទំនាក់ទំនងមួយទទួលបន្ទុកចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងអនុសញ្ញានេះ ។

(គ) ចែករំលែក និងផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិប្បធម៌ ។

មាត្រា ១០.- ការអប់រំ និងចំណាប់អារម្មណ៍របស់សាធារណជន

រដ្ឋភាគីទាំងអស់ ៖

(ក) បង្កលក្ខណៈងាយស្រួល និងរីកវិស្សការយល់ដឹងពីសារៈសំខាន់នៃការការពារ និងលើកស្ទួយវិប្បធម៌ ជាពិសេសតាមរយៈកម្មវិធីអប់រំ និងធ្វើឱ្យសាធារណជនមានចំណាប់អារម្មណ៍កាន់តែខ្លាំងក្លាឡើង

(ខ) សហប្រតិបត្តិការជាមួយរដ្ឋភាគីដទៃទៀត និងអង្គការអន្តរជាតិក៏ដូចជា អង្គការក្នុងតំបន់ ដើម្បីសម្រេចឱ្យបាននូវគោលដៅនៃមាត្រានេះ

(គ) យកចិត្តទុកដាក់លើកទឹកចិត្តដល់គំនិតច្នៃប្រឌិតបង្កើតថ្មី និងពង្រឹងសមត្ថភាពផលិតកម្មតាមរយៈការបង្កើតឱ្យមានកម្មវិធីអប់រំ ការបណ្តុះបណ្តាល និងការផ្លាស់ប្តូរនៅក្នុងវិស័យឧស្សាហកម្មវប្បធម៌ ។ វិធានការទាំងនេះគប្បីត្រូវអនុវត្តធ្វើយ៉ាងណាកុំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ទម្រង់ផលិតកម្មជាលក្ខណៈប្រពៃណី ។

មាត្រា ១១.- ការចូលរួមរបស់សង្គមស៊ីវិល

រដ្ឋភាគីទាំងអស់ទទួលស្គាល់តួនាទីជាមូលដ្ឋានរបស់សង្គមស៊ីវិល នៅក្នុងការការពារ និងការលើកស្ទួយភាពផ្សេងៗគ្នានៃវិប្បធម៌ ។ រដ្ឋភាគីទាំងអស់ត្រូវលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មរបស់សង្គមស៊ីវិលដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឱ្យបានតាមគោលដៅនៃអនុសញ្ញានេះ ។

មាត្រា ១២.- ការលើកស្ទួយកិច្ចសហប្រតិបត្តិការអន្តរជាតិ

រដ្ឋភាគីទាំងអស់ត្រូវខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី កម្រិតតំបន់ និង អន្តរជាតិ ដើម្បីបង្កើតលក្ខខណ្ឌសមស្របដល់ការលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដោយយកចិត្តទុកដាក់ជាពិសេសដល់ស្ថានភាព ដូចបានចែងនៅក្នុងមាត្រា ៨ និងមាត្រា ១៧ ក្នុងគោលដៅ :

(ក) សម្រួលកិច្ចទំនាក់ទំនងរវាងរដ្ឋភាគីនីមួយៗស្តីពីគោលនយោបាយវប្បធម៌

(ខ) ពង្រឹងសមត្ថភាពជាយុទ្ធសាស្ត្រ និងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈនៅក្នុងស្ថាប័នវប្បធម៌សាធារណៈ អាស្រ័យដោយការផ្លាស់ប្តូរវប្បធម៌តាមបេក្ខភាពវិជ្ជាជីវៈ និងជាអន្តរជាតិ ព្រមទាំងការចែករំលែកនូវការអនុវត្តន៍ដ៏ល្អប្រសើរបំផុត

(គ) ពង្រឹងភាពជាដៃគូជាមួយសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន និងរវាងអង្គភាពទាំងនេះ ដើម្បីបង្កលក្ខណៈងាយស្រួល និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌

(ឃ) លើកស្ទួយការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងជំរុញភាពជាដៃគូ ដើម្បីពង្រឹងការចែករំលែកព័ត៌មាន និងការយល់ដឹងផ្នែកវប្បធម៌ និងដើម្បីបង្កលក្ខណៈងាយស្រួលដល់ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌

(ង) ជំរុញឱ្យមានការចុះកិច្ចព្រមព្រៀងសហផលិតកម្ម និងសហចែកចាយ ។

មាត្រា ១៣.- សមាហរណកម្មវប្បធម៌នៅក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព

រដ្ឋភាគីទាំងអស់ត្រូវប្រឹងប្រែងធ្វើសមាហរណកម្មវប្បធម៌នៅក្នុងគោលនយោបាយអភិវឌ្ឍន៍របស់ខ្លួននៅគ្រប់កម្រិតថ្នាក់ ដើម្បីបង្កើតលក្ខខណ្ឌសមស្របដល់ការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព និងនៅក្នុងក្របខ័ណ្ឌនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ទិដ្ឋភាពនានាពាក់ព័ន្ធនឹងការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។

មាត្រា ១៤.- កិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍

រដ្ឋភាគីទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការគាំទ្រកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ ដោយផ្សារភ្ជាប់ពាក់ព័ន្ធនឹងតម្រូវការពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍ សំដៅសម្រួលដល់ការលេចឡើងនូវវិស័យវប្បធម៌ដ៏រស់រវើកក្នុងចំណោមវិស័យដទៃទៀត តាមរយៈមធ្យោបាយដូចខាងក្រោម :

(ក) ការពង្រឹងឧស្សាហកម្មវប្បធម៌របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ :

(១) ដោយបង្កើត និងពង្រឹងសមត្ថភាពផលិត និងសមត្ថភាពចែកចាយវប្បធម៌នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍

(២) ដោយជួយសម្រួលលការបញ្ជ្រាបចូលបានយ៉ាងទូលំទូលាយនូវសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ទៅក្នុងទីផ្សារពិភពលោក និងទៅក្នុងបណ្តាញចែកចាយជាអន្តរជាតិ

(៣) ដោយអនុញ្ញាតឱ្យមានការលេចឡើងនូវទីផ្សារក្នុងស្រុក និងថ្នាក់តំបន់ជាលក្ខណៈចីរភាព

(៤) ដោយអនុម័តទទួលយកវិធានការសមស្របតាមដែលអាចធ្វើទៅបាន នៅក្នុងប្រទេសអភិវឌ្ឍន៍ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបញ្ជ្រាបចូលទៅក្នុងដែនដីរបស់ខ្លួននូវសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌របស់ប្រទេសកំពុងអភិវឌ្ឍន៍

(៥) ដោយគាំទ្រការងារច្នៃប្រឌិតបង្កើតថ្មីនិងដោយបង្កលក្ខណៈងាយស្រួលដល់ការបំលាស់ទីរបស់សិល្បករនៃប្រទេសកំពុងអភិវឌ្ឍន៍ តាមដែលអាចធ្វើទៅបាន

(៦) ដោយជំរុញកិច្ចប្រតិបត្តិការសមស្របរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសនៅក្នុងវិស័យតូរ្យតន្ត្រី និងវិស័យភាពយន្ត

(ខ) ការពង្រឹងសមត្ថភាព តាមរយៈការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងកោសល្យវិច័យ ព្រមទាំងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងវិស័យសាធារណៈ និងឯកជនពាក់ព័ន្ធ ជាពិសេសនឹងសមត្ថភាពជាយុទ្ធសាស្ត្រ និងសមត្ថភាពគ្រប់គ្រងតាមរយៈការរៀបចំគាក់តែង និងការអនុវត្តគោលនយោបាយការលើកស្ទួយ និងការចែកចាយវិញ្ញត្តិវប្បធម៌ ការអភិវឌ្ឍសហគ្រាសខ្នាតមធ្យម ខ្នាតតូច និងមីក្រូសហគ្រាស ការប្រើប្រាស់បច្ចេកវិទ្យា ព្រមទាំងការអភិវឌ្ឍ និងការផ្ទេរសមត្ថភាព

(គ) ការផ្ទេរបច្ចេកវិទ្យា និងចំណេះធ្វើតាមរយៈការបង្កើតវិធានការលើកទឹកចិត្តសមស្រប ជាពិសេសនៅក្នុងវិស័យឧស្សាហកម្ម និងសហគ្រាសវប្បធម៌

(ឃ) ការគាំទ្រផ្នែកហិរញ្ញវត្ថុ តាមមធ្យោបាយ :

(១) បង្កើតមូលនិធិអន្តរជាតិសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ ដូចមានចែងនៅក្នុងមាត្រា ១៨

(២) ផ្តល់ជំនួយសាធារណៈដល់ការអភិវឌ្ឍ ទៅតាមតម្រូវការ រួមទាំងជំនួយបច្ចេកទេស សម្រាប់ជំរុញ និងគាំទ្រគំនិតច្នៃប្រឌិតបង្កើតថ្មី

(៣) ទម្រង់ផ្សេងៗទៀតនៃជំនួយហិរញ្ញវត្ថុ ដូចជាការខ្ចីប្រាក់មានអត្រាការប្រាក់ទាបឧបត្ថម្ភធន និងយន្តការផ្តល់ហិរញ្ញប្បទានដទៃទៀត ។

មាត្រា ១៥.- **បែបបទនៃកិច្ចសហប្រតិបត្តិការ**

រដ្ឋភាគីលើកទឹកចិត្តដល់ការអភិវឌ្ឍភាពជាដៃគូ រវាងវិស័យសាធារណៈ និងវិស័យឯកជន និងអង្គការមានគោលដៅមិនស្វែងរកប្រាក់ចំណេញ និងក្នុងរង្វង់ដែនដីរបស់ខ្លួន ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សំដៅពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការការពារ និងលើកស្ទួយ ភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ។ ជាកិច្ចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ភាពជាដៃគូប្រកបដោយលក្ខណៈច្នៃប្រឌិតទាំងនេះនឹងសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធនធានមនុស្ស និងគោលនយោបាយ ព្រមទាំងទៅលើការផ្លាស់ប្តូរសកម្មភាព ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌ ។

មាត្រា ១៦.- **ភាពអនុគ្រោះចំពោះប្រទេសកំពុងអភិវឌ្ឍន៍**

ប្រទេសអភិវឌ្ឍន៍បង្កលក្ខណៈងាយស្រួលដល់ការផ្លាស់ប្តូរវប្បធម៌ ជាមួយនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដោយផ្តល់នូវភាពអនុគ្រោះដល់សិល្បករ អ្នកវិជ្ជាជីវៈ និងអ្នកអនុវត្តខាងវប្បធម៌ដទៃទៀត ព្រមទាំងដល់ទ្រព្យសម្បត្តិ និងសេវាកម្មវប្បធម៌របស់ប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌគតិយុត្តសមស្រប ។

មាត្រា ១៧.- **កិច្ចសហប្រតិបត្តិការអន្តរជាតិស្ថិតក្នុងស្ថានភាពគំរាមកំហែងធ្ងន់ធ្ងរ ប្រឆាំងនឹងវិញ្ញត្តិវប្បធម៌**

រដ្ឋភាគីទាំងអស់ធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីជួយគ្នាទៅវិញទៅមកដោយយកចិត្តទុកដាក់ជាពិសេសទៅលើប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងស្ថានភាពដូចមានចែងក្នុងមាត្រា ៨ ។

មាត្រា ១៨.- **មូលនិធិអន្តរជាតិសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌**

១- ត្រូវបានបង្កើតមូលនិធិអន្តរជាតិមួយសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ ដែលតទៅនេះត្រូវបានហៅកាត់ថា "មូលនិធិ" ។

២- មូលនិធិនេះ គឺជាមូលនិធិដាក់បញ្ញើដោយអនុលោមទៅតាមបទបញ្ញាហិរញ្ញវត្ថុរបស់អង្គការយូណេស្កូ ។

៣- ធនធានមូលនិធិមានប្រភពមកពី :

(ក) ប្រាក់វិភាគទានស្ម័គ្រចិត្តផ្តល់ដោយរដ្ឋភាគីទាំងឡាយ

(ខ) មូលនិធិដែលផ្តល់ឱ្យក្នុងគោលបំណងនេះដោយសន្និសីទកំពូលរបស់អង្គការយូណេស្កូ

(គ) ប្រាក់ហិរញ្ញទាន ប្រាក់អំណោយ ឬអច្ច័យទានដែលអាចត្រូវបានផ្តល់ឱ្យដោយរដ្ឋដទៃទៀត ដោយអង្គការនានា និងដោយកម្មវិធីរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ អង្គការក្នុងតំបន់ ឬអង្គការអន្តរជាតិ និងអង្គការសាធារណៈ ឬអង្គការឯកជន ឬបុគ្គលជាឯកជន

(ឃ) ការប្រាក់ទាំងអស់ដែលជាប់ពាក់ព័ន្ធទៅនឹងធនធាននៃ " មូលនិធិ "

(ង) ប្រាក់ចំណូលបានមកពីការរៃអង្គាស និងប្រាក់កម្រៃបានមកពីការសំដែងនានាដែលរៀបចំឡើងដើម្បីប្រយោជន៍នៃមូលនិធិ

(ច) ធនធានដទៃទៀតទាំងអស់ដែលអនុញ្ញាតដោយបទបញ្ជារបស់មូលនិធិ ។

៤- ការប្រើប្រាស់ធនធានមូលនិធិត្រូវសម្រេចដោយគណៈកម្មាធិការអន្តររដ្ឋាភិបាល ដោយផ្អែកទៅលើការតម្រង់ទិសពីសន្និសីទរបស់រដ្ឋភាគី ដូចមានចែងក្នុងមាត្រា ២២ ។

៥- គណៈកម្មាធិការអន្តររដ្ឋាភិបាលអាចយល់ព្រមទទួលយកវិភាគទាន និងជំនួយឧបត្ថម្ភក្រោមទម្រង់ដទៃទៀត ក្នុងគោលបំណងទូទៅ ឬពិសេសដែលពាក់ព័ន្ធនឹងគម្រោងជាក់លាក់ ឱ្យតែគម្រោងទាំងនេះត្រូវបានអនុម័តដោយគណៈកម្មាធិការនេះ ។

៦- ការផ្តល់វិភាគទានផ្សេងៗដល់មូលនិធិមិនអាចភ្ជាប់ទៅនឹងល័ក្ខខ័ណ្ឌនយោបាយ សេដ្ឋកិច្ច ឬរូបភាពផ្សេងៗទៀត ដែលមានលក្ខណៈវិសមិតភាពនឹងគោលដៅរបស់អនុសញ្ញានេះឡើយ ។

៧- រដ្ឋភាគីទាំងឡាយត្រូវយកចិត្តទុកដាក់ផ្តល់វិភាគទានស្ម័គ្រចិត្តជាទៀងទាត់ ដើម្បីឱ្យអនុសញ្ញានេះអាចអនុវត្តបានសម្រេច ។

មាត្រា ១៩.- ការផ្លាស់ប្តូរ ការវិភាគ និងការផ្សព្វផ្សាយព័ត៌មាន

១- រដ្ឋភាគីទាំងអស់យល់ព្រមផ្លាស់ប្តូរព័ត៌មាន និងកោសល្យវិច័យ ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ និងស្ថិតិ ស្តីពីភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ព្រមទាំងការអនុវត្តដ៏ល្អប្រសើរ ដើម្បីការការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌

២- អង្គការយូណេស្កូបង្កលក្ខណៈងាយស្រួលដល់ការប្រមូល ការវិភាគ និងការផ្សព្វផ្សាយព័ត៌មាន ស្ថិតិ និងការអនុវត្តដ៏ល្អប្រសើរទាំងអស់ក្នុងវិស័យនេះ តាមរយៈយន្តការដែលមានស្រាប់នៅក្នុងលេខាធិការដ្ឋាន

៣- ម្យ៉ាងវិញទៀត អង្គការយូណេស្កូបង្កើត និងធ្វើបច្ចុប្បន្នភាពធនាគារទិន្នន័យពាក់ព័ន្ធនឹងវិស័យផ្សេងៗ និងអង្គការរដ្ឋាភិបាល អង្គការឯកជន និងអង្គការមានគោលដៅមិនស្វែងរកប្រាក់ចំណេញនានា ដែលធ្វើសកម្មភាពនៅក្នុងវិស័យនៃវិញ្ញត្តិវប្បធម៌

៤- ដើម្បីសំរួលដល់ការប្រមូលទិន្នន័យផ្សេងៗ អង្គការយូណេស្កូផ្តោតការយកចិត្តទុកដាក់ជាពិសេសមួយលើការពង្រឹងសមត្ថភាព និងកោសល្យវិច័យរបស់រដ្ឋភាគីទាំងអស់ដែលលើកសំណើសុំជំនួយពាក់ព័ន្ធនឹងបញ្ហានេះ

៥- ការប្រមូលព័ត៌មានដែលបានកំណត់នៅក្នុងមាត្រានេះ បំពេញបន្ថែមព័ត៌មានដែលមានចែងនៅក្នុងបទប្បញ្ញត្តិ នៃមាត្រា ៩ ។

ជំពូកទី ៥
ទំនាក់ទំនងជាមួយលិខិតូបករណ៍ដទៃទៀត

មាត្រា ២០.- ទំនាក់ទំនងជាមួយលិខិតូបករណ៍ដទៃទៀត : ការគាំទ្រគ្នាទៅវិញទៅមក ការបំពេញបន្ថែម និងការមិនចំណុះគ្នា

១- រដ្ឋភាគីទាំងអស់ទទួលស្គាល់ថាខ្លួនត្រូវបំពេញដោយសុទ្ធចិត្តនូវកាតព្វកិច្ចរបស់ពួកគេ យោងតាមអនុសញ្ញានេះ និងសន្ធិសញ្ញាដទៃទៀតទាំងអស់ដែលខ្លួនជាភាគី ។ ដូច្នេះមិនត្រូវដាក់អនុសញ្ញានេះឱ្យនៅចំណុះនឹងសន្ធិសញ្ញាដទៃទៀតឡើយ

(ក) រដ្ឋភាគីទាំងអស់លើកទឹកចិត្តដល់ការគាំទ្រគ្នាទៅវិញទៅមករវាងអនុសញ្ញានេះ និងសន្ធិសញ្ញាដទៃទៀតដែលខ្លួនជាភាគី ហើយ

(ខ) នៅពេលដែលរដ្ឋភាគីបកស្រាយ និងអនុវត្តសន្ធិសញ្ញាដទៃទៀតដែលខ្លួនជាភាគី ឬនៅពេលដែលរដ្ឋភាគីត្រូវបានចងភ្ជាប់ដោយកាតព្វកិច្ចអន្តរជាតិផ្សេងទៀត រដ្ឋភាគីទាំងឡាយនោះ ត្រូវយកចិត្តទុកដាក់ទៅលើបទប្បញ្ញត្តិច្បាស់លាស់ នៃអនុសញ្ញានេះ ។

២- គ្មានចំណុចណាមួយនៅក្នុងអនុសញ្ញានេះអាចត្រូវបានបកស្រាយថាជាការកែប្រែសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគី ឱ្យស្របតាមសន្ធិសញ្ញាដទៃទៀតដែលខ្លួនជាភាគីឡើយ ។

មាត្រា ២១.- ការព្រមព្រៀង និងការសម្របសម្រួលអន្តរជាតិ

រដ្ឋភាគីទាំងអស់សន្យាលើកស្ទួយគោលដៅ និងគោលការណ៍នៃអនុសញ្ញានេះ នៅក្នុងវេទិកាអន្តរជាតិដទៃទៀត ។ ដើម្បីសម្រេចគោលដៅនេះ បណ្តារដ្ឋភាគីធ្វើការពិគ្រោះយោបល់គ្នាប្រសិនបើអាចធ្វើទៅបាន ដោយប្រកាន់ភ្ជាប់នូវស្មារតីនៃគោលដៅ និងគោលការណ៍ទាំងនេះ ។

ជំពូកទី ៦
អង្គការនៃអនុសញ្ញា

មាត្រា ២២.- សន្និសីទរដ្ឋភាគី

១- ត្រូវបានបង្កើតសន្និសីទរដ្ឋភាគីមួយ ដែលជាអង្គការពេញអង្គ និងកំពូលនៃអនុសញ្ញានេះ ។

២- សន្និសីទរដ្ឋភាគីធ្វើការប្រជុំជាសម័យប្រជុំសាមញ្ញ រៀងរាល់ពីរឆ្នាំម្តង តាមដែលអាចធ្វើទៅបាន នៅក្នុងក្របខ័ណ្ឌនៃសន្និសីទកំពូលរបស់អង្គការយូណេស្កូ ។ សន្និសីទរដ្ឋភាគីអាចធ្វើការប្រជុំជាសម័យប្រជុំវិសាមញ្ញបាន ប្រសិនបើសន្និសីទធ្វើការសម្រេចដូច្នេះ ឬប្រសិនបើមានសំណើផ្ញើទៅគណៈកម្មាធិការអន្តររដ្ឋាភិបាល ដោយរដ្ឋភាគីចំនួនយ៉ាងហោចណាស់មួយភាគបី ។

៣- សន្និសីទរដ្ឋភាគីធ្វើការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤- សន្និសីទរដ្ឋភាគីមានមុខងារដូចតទៅ ៖

(ក) បោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាល

(ខ) ទទួល និងពិនិត្យរបាយការណ៍របស់បណ្តារដ្ឋភាគីនៃអនុសញ្ញានេះ ដែលបានផ្ញើទៅដោយគណៈកម្មាធិការអន្តររដ្ឋាភិបាល

(គ) អនុម័តសេចក្តីណែនាំប្រតិបត្តិដែលរៀបចំឡើងដោយគណៈកម្មាធិការអន្តររដ្ឋាភិបាលតាមសំណើរបស់ខ្លួន

(ឃ) ចាត់វាល់វិធានការដែលខ្លួនយល់ថាមានការចាំបាច់ ដើម្បីលើកស្ទួយគោលដៅនៃអនុសញ្ញានេះ ។

មាត្រា ២៣.- គណៈកម្មាធិការអន្តររដ្ឋាភិបាល

១- ត្រូវបានបង្កើតនៅក្នុងអង្គការយូណេស្កូនូវគណៈកម្មាធិការអន្តររដ្ឋាភិបាលមួយ ដើម្បីការពារ និងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌ ដែលតទៅនេះត្រូវបានហៅថា "គណៈកម្មាធិការអន្តររដ្ឋាភិបាល" ។ គណៈកម្មាធិការនេះមានសមាសភាពតំណាងមកពីរដ្ឋចំនួន ១៨ ជាភាគីនៃអនុសញ្ញានេះ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិបួនឆ្នាំដោយសន្និសីទរដ្ឋភាគី ចាប់តាំងពីពេលដែលអនុសញ្ញានេះចូលជាធរមាន អនុលោមតាមមាត្រា ២៩ ។

២- គណៈកម្មាធិការអន្តររដ្ឋាភិបាលធ្វើការប្រជុំម្តងក្នុងមួយឆ្នាំ ។

៣- គណៈកម្មាធិការអន្តររដ្ឋាភិបាលដំណើរការក្រោមអំណាចនៃការគ្រប់គ្រង និងស្របតាមសេចក្តីណែនាំនៃសន្និសីទរដ្ឋភាគី ហើយត្រូវរាយការណ៍ជូនសន្និសីទនេះ ។

៤- គណៈកម្មាធិការអន្តររដ្ឋាភិបាលនឹងមានសមាជិកកើនឡើងដល់ចំនួន ២៤ នៅពេលដែលចំនួនរដ្ឋភាគីនៃអនុសញ្ញានេះនឹងកើនឡើងរហូតដល់ ៥០ រដ្ឋ ។

៥- ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាលត្រូវធ្វើឡើង ដោយផ្អែកទៅលើគោលការណ៍នៃការបែងចែកទីតាំងភូមិសាស្ត្រប្រកបដោយសមធម៌ និងផ្លាស់ប្តូរវេនគ្នា ។

៦-ដោយមិនគិតដល់ភារកិច្ចផ្សេងៗទៀតដែលអនុសញ្ញានេះប្រគល់ទៅឱ្យគណៈកម្មាធិការ មុខងាររបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលមានដូចតទៅ ៖

(ក) លើកស្ទួយគោលដៅនៃអនុសញ្ញានេះ លើកទឹកចិត្ត និងធ្វើការតាមដានការអនុវត្តអនុសញ្ញានេះ

(ខ) រៀបចំ និងដាក់ជូនសន្និសីទរដ្ឋភាគីដើម្បីអនុម័ត ទៅតាមសំណើរបស់សន្និសីទនូវសេចក្តីណែនាំប្រតិបត្តិពាក់ពន្ធ័នឹងការរៀបចំ និងការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ

(គ) ផ្ញើជូនសន្និសីទរដ្ឋភាគីនូវរបាយការណ៍របស់រដ្ឋភាគីអនុសញ្ញា រួមមានការវាយតម្លៃរបស់គណៈកម្មាធិការ និងខ្លឹមសារសង្ខេបនៃរបាយការណ៍ទាំងនោះផង

(ឃ) ផ្តល់អនុសាសន៍សមស្រប នៅក្នុងស្ថានភាពដែលរដ្ឋភាគីនៃអនុសញ្ញាបាននាំមក ចំពោះអារម្មណ៍របស់គណៈកម្មាធិការ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញា ជាពិសេសមាត្រា ៨

(ង) រៀបចំបង្កើតនីតិវិធី និងយន្តការពិគ្រោះយោបល់ផ្សេងៗទៀត ដើម្បីលើកស្ទួយគោលដៅ និងគោលការណ៍នៃអនុសញ្ញានេះ នៅក្នុងវេទិកាអន្តរជាតិដទៃទៀត

(ច) បំពេញរាល់កិច្ចការទាំងអស់ដែលសន្និសីទរដ្ឋភាគីអាចប្រគល់ឱ្យ ។

៧- យោងទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន គណៈកម្មាធិការអន្តររដ្ឋាភិបាលអាចអញ្ជើញអង្គការសាធារណៈ ឬអង្គការឯកជន ឬរូបវន្តបុគ្គលនៅគ្រប់ពេលទាំងអស់ ឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិគ្រោះយោបល់ទៅលើបញ្ហាពិសេសដោយឡែកផ្សេងៗ ។

៨- គណៈកម្មាធិការអន្តររដ្ឋាភិបាលធ្វើការតាក់តែងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ហើយដាក់ជូនសន្និសីទរដ្ឋភាគីធ្វើការអនុម័ត ។

មាត្រា ២៤.- **លេខាធិការដ្ឋានអង្គការយូណេស្កូ**

១- អង្គការនៃអនុសញ្ញានេះមានជំនួយពីលេខាធិការដ្ឋានអង្គការយូណេស្កូ ។

២- លេខាធិការដ្ឋានរៀបចំឯកសាររបស់សន្និសីទរដ្ឋភាគី និងឯកសាររបស់គណៈកម្មាធិការអន្តររដ្ឋាភិបាល ព្រមទាំងសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំ ជួយដល់ការអនុវត្តនៃសេចក្តីសម្រេចរបស់ពួកគេ និងធ្វើរបាយការណ៍ពីការអនុវត្តនេះ ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ២៥.- ការដោះស្រាយវិវាទ

១- ក្នុងករណីមានវិវាទកើតឡើងរវាងរដ្ឋភាគីនៃអនុសញ្ញានេះ ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញា រដ្ឋភាគីត្រូវស្វែងរកដំណោះស្រាយមួយ តាមរយៈការចរចា ។

២- ប្រសិនបើរដ្ឋភាគីពាក់ព័ន្ធទាំងអស់មិនអាចឈានទៅដល់ការព្រមព្រៀងតាមរយៈការចរចាបានទេ ពួកគេអាចព្រមព្រៀងគ្នាស្វែងរកអន្តរាគមន៍ផ្សះផ្សាពីខាងក្រៅ ឬស្នើសុំឱ្យតតិយជនជួយសម្រុះសម្រួល ។

៣- ប្រសិនបើគ្មានអន្តរាគមន៍ផ្សះផ្សា ឬសម្រុះសម្រួលទេ ឬប្រសិនបើវិវាទមិនអាចដោះស្រាយតាមរយៈការចរចា អន្តរាគមន៍ផ្សះផ្សា ឬសម្រុះសម្រួលបានទេ រដ្ឋភាគីមួយអាចស្វែងរកជំនួយផ្សះផ្សា ដោយអនុលោមទៅតាមនីតិវិធីដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញានេះ ។ រដ្ឋភាគីទាំងអស់ត្រូវតែពិនិត្យដោយសុទ្ធចិត្តនូវសំណើដំណោះស្រាយវិវាទ ដែលលើកឡើងដោយគណៈកម្មការផ្សះផ្សា ។

៤- នៅពេលឱ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក រដ្ឋភាគីនីមួយៗ អាចប្រកាសថា ខ្លួនមិនទទួលស្គាល់នីតិវិធីផ្សះផ្សាដែលមានចែងខាងលើទេ ។ រដ្ឋភាគីទាំងឡាយណាដែលបានធ្វើសេចក្តីប្រកាសបែបនេះរួចហើយ អាចដកសេចក្តីប្រកាសនោះវិញ នៅគ្រប់ពេលដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយកអង្គការយូណេស្កូ ។

មាត្រា ២៦.- ការឱ្យសច្ចាប័ន ការយល់ព្រមទទួលយក ការឯកភាព ឬការចូលជាសមាជិកដោយរដ្ឋជាសមាជិក

១- អនុសញ្ញានេះត្រូវបានដាក់ជូនរដ្ឋជាសមាជិករបស់អង្គការយូណេស្កូ ដើម្បីឱ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ដោយអនុលោមទៅតាមនីតិវិធីរដ្ឋធម្មនុញ្ញរបស់រដ្ឋទាំងនោះរៀងៗខ្លួន ។

២- លិខិតូបករណ៍ធ្វើសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ត្រូវបានតំកល់ទុកនៅអគ្គនាយកអង្គការយូណេស្កូ ។

មាត្រា ២៧.- ការចូលជាសមាជិក

១- អនុសញ្ញានេះបើកចំហដល់បណ្តារដ្ឋទាំងឡាយ ដែលមិនមែនជាសមាជិករបស់អង្គការយូណេស្កូ ឱ្យចូលជាសមាជិក ប៉ុន្តែរដ្ឋទាំងនោះត្រូវតែជាសមាជិករបស់អង្គការសហប្រជាជាតិ ឬជាសមាជិកនៃស្ថាប័នជំនាញមួយក្នុងចំណោមស្ថាប័នជំនាញផ្សេងៗរបស់អង្គការសហប្រជាជាតិដែលត្រូវបានអញ្ជើញឱ្យចូលជាសមាជិកនៃអនុសញ្ញានេះដោយសន្និសីទកំពូលរបស់អង្គការ ។

២- អនុសញ្ញានេះក៏បើកចំហឱ្យចូលជាសមាជិកផងដែរ ចំពោះដែនដីដែលមានស្វ័យភាពផ្ទៃក្នុងពេញលេញ ដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់មានឯករាជ្យភាពពេញលេញ អនុលោមតាមសេចក្តីសម្រេចលេខ ១៥១៤ (XV) នៃមហាសន្និបាត និងមានសមត្ថកិច្ចចំពោះវិស័យដែលអនុសញ្ញានេះយកចិត្តទុកដាក់លើ រួមទាំងសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងវិស័យទាំងនេះផង ។

៣- បទប្បញ្ញត្តិខាងក្រោមនេះអនុវត្តទៅលើអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ :

(ក) អនុសញ្ញានេះក៏បើកចំហឱ្យចូលជាសមាជិកផងដែរ ចំពោះអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ទាំងឡាយណាដែលចងកាតព្វកិច្ចពេញលេញដោយបទប្បញ្ញត្តិ នៃអនុសញ្ញានេះ ដូចគ្នានឹងបណ្តារដ្ឋភាគីផងដែរ លើកលែងតែអញ្ញត្រកម្មដែលមានចែងក្នុងកថាខ័ណ្ឌនានាខាងក្រោម

(ខ) នៅពេលរដ្ឋមួយ ឬច្រើនដែលជាសមាជិកអង្គការបែបនេះ ក៏ជាភាគីនៃអនុសញ្ញានេះដែរ អង្គការ និងរដ្ឋជាសមាជិកទាំងនេះ បានព្រមព្រៀងទៅតាមការទទួលខុសត្រូវរបស់ខ្លួន ក្នុងការអនុវត្តកាតព្វកិច្ចរបស់ពួកគេ ស្របតាមអនុសញ្ញានេះ ។ ការបែងចែកការទទួលខុសត្រូវនេះមានអានុភាពនៅពេលបញ្ចប់នីតិវិធី នៃការ

ជូនដំណឹងជាលាយលក្ខណ៍អក្សរ ដូចមានរៀបរាប់ក្នុងវាក្យខ័ណ្ឌ (ខ) ។ អង្គការ និងរដ្ឋជាសមាជិកមិនមាននីតិសម្បទាក្នុងការអនុវត្តរួមគ្នានូវសិទ្ធិ ដែលកើតចេញពីអនុសញ្ញានេះឡើយ ។ ម្យ៉ាងវិញទៀតនៅក្នុងវិស័យដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មានចំនួនសំឡេងឆ្នោតស្មើនឹងចំនួនរដ្ឋជាសមាជិកដែលជាភាគីនៃអនុសញ្ញានេះ ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន ។ អង្គការទាំងនេះមិនអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនឡើយ ប្រសិនបើរដ្ឋជាសមាជិកនៃអង្គការនេះអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន និងផ្ទុយមកវិញ

(គ) អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ និងរដ្ឋជាសមាជិករបស់ខ្លួនដែលបានព្រមព្រៀងឱ្យមានការបែងចែកការទទួលខុសត្រូវដូចដែលបានចែងនៅក្នុងវាក្យខ័ណ្ឌ (ខ) ផ្តល់ដំណឹងដល់ភាគីទាំងអស់ពីការបែងចែកនេះ តាមវិធីដូចខាងក្រោម :

១- នៅក្នុងលិខិតូបករណ៍ចូលជាសមាជិក អង្គការនេះបញ្ជាក់យ៉ាងច្បាស់លាស់ពីការបែងចែកការទទួលខុសត្រូវពាក់ព័ន្ធនឹងបញ្ហាដែលគ្រប់គ្រងដោយអនុសញ្ញា

២- ក្នុងករណីមានការកែប្រែការទទួលខុសត្រូវរៀងៗខ្លួននៅពេលក្រោយ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវផ្តល់ដំណឹងដល់អ្នកតំកល់ឯកសារនូវរាល់សំណើកែប្រែការទទួលខុសត្រូវទាំងនេះ ។ រីឯអ្នកតំកល់ឯកសារវិញត្រូវជូនដំណឹងទៅភាគីទាំងអស់ពីការកែប្រែនេះ

(ឃ) បណ្តារដ្ឋជាសមាជិកនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ដែលក្លាយទៅជាភាគីនៃអនុសញ្ញានេះ ត្រូវចាត់ទុកថាខ្លួននៅតែមានសមត្ថកិច្ចក្នុងគ្រប់វិស័យដែលមិនមែនជាកម្មវត្ថុនៃការផ្ទេរសមត្ថកិច្ចទៅឱ្យអង្គការដែលត្រូវបានប្រកាស ឬជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យអ្នកតំកល់ឯកសារ

(ង) ពាក្យថា "អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់" សំដៅដល់អង្គការមួយដែលបង្កើតឡើងដោយបណ្តារដ្ឋអធិបតេយ្យជាសមាជិករបស់អង្គការសហប្រជាជាតិ ឬស្ថាប័នជំនាញមួយក្នុងចំណោមស្ថាប័នជំនាញទាំងឡាយរបស់អង្គការសហប្រជាជាតិដែលរដ្ឋទាំងនេះបានផ្ទេរសមត្ថកិច្ចរបស់ខ្លួនទៅក្នុងវិស័យ ដែលគ្រប់គ្រងដោយអនុសញ្ញានេះ ហើយដែលត្រូវបានអនុញ្ញាតយ៉ាងត្រឹមត្រូវឱ្យក្លាយទៅជាភាគីយោងតាមនីតិវិធីផ្ទៃក្នុង ។

៤- លិខិតូបករណ៍ចូលជាសមាជិកត្រូវបានតំកល់ទុកនៅអគ្គនាយកអង្គការយូណេស្កូ ។

មាត្រា ២៨.- កន្លែងទាក់ទងព័ត៌មាន

នៅពេលដែលបានក្លាយជាភាគីនៃអនុសញ្ញានេះ ភាគីនីមួយៗត្រូវកំណត់ពីកន្លែងទាក់ទងព័ត៌មាន ដូចដែលមានចែងនៅក្នុងមាត្រា ៩ ។

មាត្រា ២៩.- ការចូលជាធរមាន

១- អនុសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយកាលបរិច្ឆេទ នៃការតំកល់លិខិតូបករណ៍ឱ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិកលើកទី៣០ ប៉ុន្តែការធ្វើបែបនេះ គឺចំពោះតែរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលបានតំកល់លិខិតូបករណ៍ធ្វើសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិករបស់ខ្លួន តាមកាលបរិច្ឆេទនោះឬមុនពេលនោះប៉ុណ្ណោះ ។ អនុសញ្ញានេះនឹងចូលជាធរមានសម្រាប់គ្រប់រដ្ឋភាគីដទៃទៀត ក្នុងរយៈពេលបីខែក្រោយពីបានតំកល់លិខិតូបករណ៍ឱ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ។

២- ដើម្បីបំពីគោលដៅនៃមាត្រានេះ គ្មានលិខិតូបករណ៍ណាមួយដែលបានតំកល់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ត្រូវបានចាត់ទុកថាមកបន្ថែមលើលិខិតូបករណ៍ដែលរដ្ឋជាសមាជិកនៃអង្គការនេះបានតំកល់ទុករួចហើយឡើយ ។

មាត្រា ៣០.- របបរដ្ឋធម្មនុញ្ញសហព័ន្ធ ឬមិនមែនរដ្ឋទោល

ដោយទទួលស្គាល់ថា កិច្ចព្រមព្រៀងអន្តរជាតិក៏ចងជាប់ដែរនូវកាតព្វកិច្ចរដ្ឋភាគី ដោយមិនអាស្រ័យនឹងប្រព័ន្ធរដ្ឋធម្មនុញ្ញរបស់ខ្លួន រាល់បទប្បញ្ញត្តិខាងក្រោមនេះអនុវត្តចំពោះរដ្ឋភាគីណាដែលមានរបបរដ្ឋធម្មនុញ្ញសហព័ន្ធ ឬមិនមែនរដ្ឋទោល :

(ក) ពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តស្ថិតក្នុងសមត្ថកិច្ចនៃអំណាចនីតិបញ្ញត្តិសហព័ន្ធ ឬអំណាចនីតិបញ្ញត្តិកណ្តាល កាតព្វកិច្ចរបស់រដ្ឋាភិបាលសហព័ន្ធ ឬរដ្ឋាភិបាលកណ្តាល គឺដូចគ្នាទៅនឹងកាតព្វកិច្ចរបស់រដ្ឋភាគីដែលមិនមែនជារដ្ឋសហព័ន្ធដែរ

(ខ) ពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តស្ថិតក្នុងសមត្ថកិច្ចនៃអង្គភាពប្រមូលផ្តុំនីមួយៗ ដូចជារដ្ឋ តំបន់(កុងតេ) ខេត្ត ឬស្រុក(កង់តុង) ដែលមិនចាំបាច់ត្រូវចាត់វិធានការច្បាប់ស្របតាមរបបរដ្ឋធម្មនុញ្ញសហព័ន្ធ ប្រសិនបើចាំបាច់ រដ្ឋាភិបាលសហព័ន្ធនឹងផ្តល់ដំណឹងពីបទប្បញ្ញត្តិទាំងនេះដល់អាជ្ញាធរមានសមត្ថកិច្ចនៃអង្គភាពប្រមូលផ្តុំ ដូចជារដ្ឋ តំបន់ (កុងតេ) ខេត្ត ឬស្រុក(កង់តុង) ដោយមានយោបល់យល់ស្រប ដើម្បីធ្វើការអនុម័ត ។

មាត្រា ៣១.- ការបដិសេធ

១- ភាគីនីមួយៗមានលទ្ធភាពបដិសេធអនុសញ្ញានេះ ។

២- ការបដិសេធត្រូវជូនដំណឹងតាមរយៈលិខិតូបករណ៍ជាលាយលក្ខណ៍អក្សរតំកល់ទុកនៅអគ្គនាយកអង្គការយូណេស្កូ ។

៣- ការបដិសេធមានសុពលភាព ក្នុងរយៈពេលដប់ពីរខែ ក្រោយពីបានទទួលលិខិតូបករណ៍បដិសេធ ។ ការបដិសេធនេះមិនកែប្រែកាតព្វកិច្ចហិរញ្ញវត្ថុដែលរដ្ឋភាគីបដិសេធត្រូវអនុវត្តរហូតដល់កាលបរិច្ឆេទនៃការដកខ្លួនចេញ មានសុពលភាព ។

មាត្រា ៣២.- មុខងាររបស់អ្នកតំកល់ឯកសារ

ក្នុងនាមជាអ្នកទទួលតំកល់ឯកសារនៃអនុសញ្ញានេះ អគ្គនាយកអង្គការយូណេស្កូត្រូវផ្តល់ព័ត៌មានទៅរដ្ឋជាសមាជិកអង្គការ រដ្ឋមិនមែនជាសមាជិក និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដូចមានចែងក្នុងមាត្រា ២៧ ព្រមទាំងអង្គការសហប្រជាជាតិ អំពីការតំកល់ទុករាល់លិខិតូបករណ៍សម្រាប់ផ្តល់សច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ដែលមានបញ្ជាក់ក្នុងមាត្រា ២៦ និង មាត្រា ២៧ និងពីការបដិសេធដែលមានចែងក្នុងមាត្រា ៣១ ។

មាត្រា ៣៣.- វិសោធនកម្ម

១- រដ្ឋភាគីនីមួយៗអាចស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរផ្ញើទៅអគ្គនាយក ។ អគ្គនាយកបញ្ជូនលិខិតនេះទៅគ្រប់រដ្ឋភាគីទាំងអស់ ។ ប្រសិនបើនៅក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនលិខិត រដ្ឋភាគីចំនួនយ៉ាងហោចណាស់ពាក់កណ្តាលបានផ្តល់ចម្លើយយល់ស្របនឹងសំណើនេះ អគ្គនាយកមានសិទ្ធិដាក់បង្ហាញសំណើនេះសម្រាប់សម័យប្រជុំរបស់សន្និសីទរដ្ឋភាគីលើកក្រោយ ដើម្បីពិភាក្សា និងធ្វើការអនុម័តជាយថាហេតុ ។

២- វិសោធនកម្មត្រូវអនុម័តដោយសំឡេងភាគច្រើនពីរភាគបីនៃរដ្ឋភាគីមានវត្តមាន និងចូលរួមបោះឆ្នោត ។

៣- នៅពេលអនុម័តរួចហើយ វិសោធនកម្មអនុសញ្ញានេះត្រូវបញ្ជូនទៅរដ្ឋភាគីទាំងអស់ ដើម្បីឱ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ។

៤- ចំពោះភាគីដែលបានឱ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក វិសោធនកម្មអនុសញ្ញានេះចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយពីបានតំកល់ទុកលិខិតូបករណ៍ដោយភាគីចំនួនពីរភាគបី ដូចដែលមានចែងក្នុងកថាខ័ណ្ឌ ៣ នៃមាត្រានេះ ។ បន្ទាប់មកទៀត ចំពោះរដ្ឋភាគីនីមួយៗដែលឱ្យសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជា

សមាជិក វិសោធនកម្មនេះចូលជាធរមាន ក្នុងរយៈពេលបីខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់ ទុកលិខិតូបករណ៍ធ្វើសច្ចាប័ន យល់ព្រមទទួលយក ឯកភាព ឬចូលជាសមាជិក ។

៥- និតិវិធីដែលបានរៀបចំឡើងនៅក្នុងកថាខ័ណ្ឌ ៣ និងកថាខ័ណ្ឌ ៤ មិនអនុវត្តចំពោះ វិសោធនកម្មមាត្រា ២៣ ពាក់ព័ន្ធនឹងចំនួនសមាជិកនៃគណៈកម្មាធិការអន្តររដ្ឋាភិបាលឡើយ ។ វិសោធនកម្មទាំងនោះចូលជាធរមាននៅពេលផ្តល់ការអនុម័តដោយរដ្ឋភាគីទាំងអស់ ។

៦- រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ក្នុងន័យនៃមាត្រា ២៧ ដែលក្លាយជា រដ្ឋភាគីនៃអនុសញ្ញានេះ បន្ទាប់ពីវិសោធនកម្មនេះចូលជាធរមាន អនុលោមទៅតាមកថាខ័ណ្ឌ ៤ នៃមាត្រានេះ ប្រសិនបើមិនមានការសំដែងចេតនាផ្សេងគ្នា ត្រូវបានចាត់ទុកថាជាៈ

(ក) រដ្ឋភាគីនៃអនុសញ្ញានេះដែលបានធ្វើវិសោធនកម្ម និង

(ខ) រដ្ឋភាគីនៃអនុសញ្ញានេះដែលមិនបានធ្វើវិសោធនកម្ម ចំពោះគ្រប់ភាគីដែលមិន បានចងកាតព្វកិច្ចដោយវិសោធនកម្មទាំងនេះ ។

មាត្រា ៣៨.- អត្ថបទសិរភាពចំពោះមុខច្បាប់

អនុសញ្ញានេះត្រូវបានរៀបចំឡើងជាភាសាអង់គ្លេស អារ៉ាប់ ចិន អេស្ប៉ាញ បារាំង និងរុស្ស៊ី ហើយអត្ថបទទាំងប្រាំមួយច្បាប់នេះ មានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ។

មាត្រា ៣៩.- ការចុះបញ្ជី

យោងទៅតាមមាត្រា១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះនឹងត្រូវចុះបញ្ជី នៅលេខាធិការដ្ឋានអង្គការសហប្រជាជាតិ តាមសំណើរបស់អគ្គនាយកអង្គការយូណេស្កូ ។

ឧបសម្ព័ន្ធ

នីតិវិធីផ្សះផ្សា

មាត្រា ១.- គណៈកម្មការផ្សះផ្សា

(b) Partie à la présente Convention non amendée à l'égard de toute Partie qui n'est pas liée par ces amendements.

Article 34 - Textes faisant foi

La présente Convention est établie en anglais, arabe, chinois, espagnol, français et russe, les six textes faisant également foi.

Article 35 - Enregistrement

Conformément à l'article 102 de la Charte des Nations Unies, la présente Convention sera enregistrée au Secrétariat de l'Organisation des Nations Unies à la requête du Directeur général de l'UNESCO.

ANNEXE

Procédure de conciliation

Article premier - Commission de conciliation

Une Commission de conciliation est créée à la demande de l'une des Parties au différend. À moins que les Parties n'en conviennent autrement, la Commission se compose de cinq membres, chaque Partie concernée en désignant deux et le Président étant choisi d'un commun accord par les membres ainsi désignés

Article 2 - Membres de la commission

En cas de différend entre plus de deux Parties, les parties ayant le même intérêt désignent leurs membres de la Commission d'un commun accord. Lorsque deux Parties au moins ont des intérêts indépendants ou lorsqu'elles sont en désaccord sur la question de savoir si elles ont le même intérêt, elles nomment leurs membres séparément

Article 3 - Nomination

Si, dans un délai de deux mois après la demande de création d'une commission de conciliation, tous les membres de la Commission n'ont pas été nommés par les Parties, le Directeur général de l'UNESCO procède, à la requête de la Partie qui a fait la demande, aux nominations nécessaires dans un nouveau délai de deux mois

Article 4 - Président de la commission

Si, dans un délai de deux mois après la nomination du dernier des membres de la Commission, celle-ci n'a pas choisi son Président, le Directeur général procède, à la requête d'une Partie, à la désignation du Président dans un nouveau délai de deux mois

Article 5 - Décisions

La Commission de conciliation prend ses décisions à la majorité des voix de ses membres. À moins que les Parties au différend n'en conviennent autrement, elle établit sa propre procédure. Elle rend une proposition de résolution du différend que les Parties examinent de bonne foi.

Article 6 - Désaccords

En cas de désaccord au sujet de la compétence de la Commission de conciliation, celle-ci décide si elle est ou non compétente.

ព្រះរាជក្រម

នស/រកម/០៧០៧/០២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់
ស្តីពី
វិសោធនកម្មមាត្រា ១៣៩
និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ

មាត្រា មួយ.-

មាត្រា ១៣៩ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

មាត្រា ១៣៩.-ថ្មី

ក្នុងករណីមានកិច្ចការប្រញាប់ខុសធម្មតា តម្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមក្រៅម៉ោងពេលធម្មតា ម៉ោងពេលបន្ថែមទាំងនេះ ត្រូវឱ្យឈ្នួលតាមអត្រាតម្លើង ៥០ ℅ (ហាសិបភាគរយ) ។ ប្រសិនបើធ្វើការបន្ថែមនៅពេលយប់ចន្លោះពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ ឬ នៅក្នុងថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ត្រូវផ្តល់ប្រាក់បន្ថែមតាមអត្រាតម្លើង ១០០ ℅ (មួយរយភាគរយ) ។

មាត្រា ១៤៤.-ថ្មី

ពាក្យថាពេលយប់ក្នុងច្បាប់នេះមានន័យថា រយៈពេល ១១ (ដប់មួយ) ម៉ោងបន្តបន្ទាប់គ្នាយ៉ាងតិច ដោយក្នុងនោះត្រូវមានពេលពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺផង ។ ការងារពេលយប់ត្រូវគិតពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ ។

ROYAUME DU CAMBODGE ... MINISTERE DU PALAIS ROYAL

ក្រៅពីការងារបន្តបន្ទាប់ដែលក្រុមកម្មករផ្លាស់វេនគ្នាធ្វើការជូនថ្ងៃ ជូនយប់ ការងារនៃសហគ្រាសអាចមានធ្វើមួយផ្នែកនៃពេលយប់ជានិច្ច ។ ការងារពេលយប់ ត្រូវឱ្យប្រាក់ឈ្នួលតាមអត្រា ១៣០ ៉ (មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួលការងារពេលថ្ងៃ ។

មាត្រា ពីរ.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រក.០៧០៧.៣១៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ហត្ថលេខា

វង សូត

លេខ: ៣០៧ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៩៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតម្លើងឋានៈស្មើ **អនុរដ្ឋលេខាធិការ** ជូនឯកឧត្តម ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឈយ ឆណ្ណី**

២- ឯកឧត្តម **ចៅ វដ្ឋា** ។

មាត្រា ២: រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ: ៣០៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ជនរោន

៣៧.០៧០៧.៣២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូន

- ឧត្តមសេនីយ៍ទោ **អ៊ុក ខៀន** អត្តលេខ ០០១២៣៩

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

លេខ:២៩៩៦.ល

៣ល.០៧០៧.៣២២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ... ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌ លោក **ឈឹម សុផាណារ៉ាត** ពីអនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងអភិវឌ្ឍន៍ជនបទ ទៅបម្រើការងារជាអនុមន្ត្រី ថ្នាក់លេខ ១៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខៈ ៣១៦ ច.ល

ចល. ០៧០៧.៣២៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៧

[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៧០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីចំនួន ០៣ រូបនៃក្រសួងយុត្តិធម៌ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **ចំនួ មនោ** ឱ្យបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២-ឯកឧត្តម **ឌុំច សំគី** ឱ្យបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌

៣-ឯកឧត្តម **ម៉ែន ពេជ្រសាលី** ឱ្យបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣/ល.០៧០៧.៣២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៧

លេខៈ ៧៦១ ច.ល

...ចម្លងចែក

...ខែ... ឆ្នាំ២០០៧

...ទីស្តីការគណៈរដ្ឋមន្ត្រី

...ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ៈ ត្រូវបានតែងតាំងទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជាចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម សៅ កុសល មានឋានៈស្មើ ទេសរដ្ឋមន្ត្រី

២- ឯកឧត្តម និត សុជាតិ មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២ៈ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ៈ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.ល.០៧០៧.៣២៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៧

លេខ: ៣១៦ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
... ឯកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/៣០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់**ឧត្តមសេនីយ៍ទោ** ជូនលោកស្រីឧត្តមសេនីយ៍ត្រី **អ៊ុខ សុគន្ធា** អត្តលេខ ០២៩៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.ល. ០៧០៧. ៣២៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៧

លេខ: ៣៦៣ ច.ល

ដើម្បីជូនចំលង

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៧

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម ជូនក្រសួង-ស្ថាប័ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ៨៣.១០៩.៩១២.៧៩៧ រៀល (ប៉ែតសិបបីពាន់មួយរយប្រាំបួនលានប្រាំបួនរយដប់ពីរពាន់ប្រាំពីររយកៅសិបប្រាំពីររៀលគត់) ទៅលើសៀវភៅថវិកាចំនួន ០៣ ក្រសួង-ស្ថាប័ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដូចខាងក្រោម :

- ក្រសួងការពារជាតិ ចំនួន ៤០ ៤៥៤.៥៦៥.៥១៣ រៀល
- ក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខសាធារណៈ ចំនួន ២៣.០៥៥.៥១៥.៨៨៤ រៀល
- ទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ១៩.៥៥៥.៨២៧.៤០១ រៀល

មាត្រា២: ឥណទានថវិកាបន្ថែមដូចក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៦០ (ការទិញ) សំរាប់ផ្តល់ជូន ចំនួន ០៣ ក្រសួង -ស្ថាប័ន សំរាប់បោះអាណត្តិទូទាត់សងបំណុលថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈ និង ឯកសណ្ឋាន ជូនក្រុមហ៊ុនសូគីមិច ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា៤: ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខកាលបើការបោះអាណត្តិទូទាត់សងបំណុលថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈ និង ឯកសណ្ឋាន ជូនក្រុមហ៊ុនសូគីមិច ត្រូវបានចប់សព្វគ្រប់ ។

មាត្រា៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ ✓

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨១.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១០.០០០ លានរៀល (ដប់ពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ជូនក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់សងបំណុលកិច្ចសន្យាផ្គត់ផ្គង់អង្ករក្នុងឆ្នាំ ២០០៣ ជូនក្រុមហ៊ុន **មែន សារុន អាហារ៍ណ នីហារ៍ណ** ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៤ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការទទួលស្គាល់វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្ដីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្ដមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ២៥៨៧ អយក.ឧស ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧

ស ម្រេ ច

មាត្រា ១.-

ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា** ជាភាសាអង់គ្លេស Institute of Social Science and Technology សរសេរកាត់ជាភាសាខ្មែរ វ.ស.ប. និង សរសេរកាត់ ជាភាសាអង់គ្លេស I.S.T ។

មាត្រា ២.-

វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា មានទីតាំងស្ថិតនៅ ភូមិកៀនសាំង ឃុំស្វាយរៀង ស្រុកស្វាយរៀង ទីរួមខេត្តស្វាយរៀង និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣.-

វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ លើមហាវិទ្យាល័យបី :

- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ
- មហាវិទ្យាល័យ ព័ត៌មានវិទ្យា
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍

វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ (ប្រាំមួយ) ខែ ។ ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខាមហាវិទ្យាល័យ មុខជំនាញ ប្រភេទបណ្តុះបណ្តាលផ្សេងទៀត ឬ ប្តូរទីតាំងថ្មី ដោយរៀបចំសំណុំឯកសារ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤.-

វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសំរេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន និងមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥.-

នាយកវិទ្យាស្ថានមានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាននេះ និងធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ។
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ស្របតាមការណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។
- គោរពតាមកិច្ចសន្យាដែលវិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា នៅខេត្តស្វាយរៀង បានសន្យាចំពោះក្រសួងអប់រំ យុវជន និងកីឡា ។

- ធ្វើរបាយការណ៍ អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

មាត្រា ៦.-

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានសង្គមសាស្ត្រ និងបច្ចេកវិទ្យា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- សាលាខេត្តស្វាយរៀង
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ អករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ស ម្រេ ច

មាត្រា ១.-

ត្រូវបានបង្កើតពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា (PREAH SIHAMONI RAJA BUDDHIST UNIVERSITY) ហៅកាត់ជាភាសាខ្មែរ "ព.ស.ស.រ" និងហៅកាត់ជាភាសាអង់គ្លេស "PSBU" ។ ពុទ្ធិកសាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា មានតួនាទី និងភារកិច្ចអប់រំ បណ្តុះបណ្តាលសមណនិស្សិត និងនិស្សិត សិក្សាស្រាវជ្រាវ ពុទ្ធសាសនា និងសាសនាឯទៀត វប្បធម៌ អក្សរសាស្ត្រ វិទ្យាសាស្ត្រសង្គម និង ព័ត៌មានវិទ្យា ។

មាត្រា ៣.-

ចំពោះមុខ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ។ កម្មវិធីសិក្សា ត្រូវមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤.-

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ដឹកនាំដោយសាកលវិទ្យាធិការមួយរូប ជាមន្ត្រីសង្ឃជាន់ខ្ពស់ គណៈធម្មយុត្តិ ដែលមានសមត្ថភាពសមស្រប និងសាកលវិទ្យាធិការរងមួយរូប ឬច្រើនរូប ជាជំនួយការ ដែលជាមន្ត្រីសង្ឃ ឬជាគ្រហស្ថ ។

មាត្រា ៥.-

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា តាមរយៈអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦.-

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា មានពុទ្ធិកមហាវិទ្យាល័យចំនួនបួន (៤) និងពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យចំនួនមួយ (១) ដូចខាងក្រោម :

- ពុទ្ធិកមហាវិទ្យាល័យទស្សនវិជ្ជា សាសនា និងនីតិសាស្ត្រ
- ពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស
- ពុទ្ធិកមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងអក្សរសាស្ត្រ
- ពុទ្ធិកមហាវិទ្យាល័យព័ត៌មានវិទ្យា ។

នៅអនាគត ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា អាចមានពុទ្ធិកមហាវិទ្យាល័យ ឯកទេស សាខា ឬ ពង្រីកកម្រិត ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៧.-

សមណនិស្សិត និងនិស្សិតដែលរៀនចប់កម្មវិធីសិក្សា របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីពុទ្ធិកសាកលវិទ្យាល័យនេះ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៨.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ខុទ្ទកាល័យសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៨៤...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរំលាយក្រុមហ៊ុនជលផលជាសហគ្រាសសាធារណៈ និងក្រុមប្រឹក្សាភិបាល

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៥ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើត គណៈកម្មាធិការជាតិអភិបាលវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

-តាមសំណើរបស់គណៈកម្មាធិការជាតិអភិបាលវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុន សំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

សម្រេច

មាត្រា ១.

រំលាយក្រុមហ៊ុនជលផលជាសហគ្រាសសាធារណៈ ដែលបង្កើតឡើងដោយអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

មាត្រា ២.-

រំលាយក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និង ប្រធានអគ្គនាយកក្រុមហ៊ុនជលផល ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

មាត្រា ៣.-

ផ្ទេរលោក **ឌូ ប៊ុនថា** ប្រធានអគ្គនាយកក្រុមហ៊ុនជលផល ចូលមកបំរើការងារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

មាត្រា ៤.-

រាល់បំណុលរ៉ាំរ៉ៃទាំងអស់ដែលអតិថិជនជំពាក់ក្រុមហ៊ុនជលផល ចំនួន ១២.៦១៦ (ដប់ពីរពាន់ប្រាំមួយរយដប់ប្រាំមួយ) ដុល្លារអាមេរិក និង ៧.៥០០ ០០០(ប្រាំពីរលានប្រាំរយពាន់)រៀល ត្រូវផ្ទេរមករដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលបន្ទុកដោះស្រាយបន្ត ។

មាត្រា ៥.-

ប្រាក់កក់របស់ក្រុមហ៊ុនជលផលសំរាប់ការតបណ្តាញអគ្គិសនី ចំនួន ៤.៧២៥.០០០ (បួនលានប្រាំពីររយម្ភៃប្រាំពាន់)រៀល ត្រូវផ្ទេរមករដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលបន្ទុកបន្ត ។

មាត្រា ៦.-

ក្រុមហ៊ុនជលផល ត្រូវប្រគល់ត្រាក្រុមហ៊ុន និង ឯកសារពាក់ព័ន្ធទាំងឡាយ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក។

មាត្រា ៧.-

ថវិកាដែលនៅសល់ក្នុងគណនីទាំងអស់របស់ក្រុមហ៊ុនជលផលត្រូវបង្វែរចូលថវិការដ្ឋ។

បិទរាល់គណនីធនាគារទាំងអស់របស់ក្រុមហ៊ុនជលផល ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

មាត្រា ៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ ។

មាត្រា ៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិអភិវឌ្ឍន៍ ក្រុមហ៊ុនជលផល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៦៥.០០០ លានរៀល (ហុកសិបប្រាំពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៦ (បន្ទុកហិរញ្ញវត្ថុ) ចំនួន ១៥.០០០ លានរៀល និងពីជំពូក ១៦ (ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១៦ (ការទូទាត់ប្រាក់ខ្ចី និង បំណុលប្រហាក់ប្រហែល) ចំនួន ៥០.០០០ លានរៀល ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់សងការប្រាក់ និងទូទាត់សងប្រាក់ដើមរហូតដល់បំណាច់ឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៨៦...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.០០០ លានរៀល (មួយពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភធន និង ជំនួយសង្គម) ជូនក្រសួងធម្មការ និង សាសនា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយដំណើរការរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកំណត់ក្របខ័ណ្ឌមន្ត្រីក្រមការ តាមលក្ខន្តិកៈដោយឡែក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល តាមលក្ខន្តិកៈដោយឡែក
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សម្រេច

មាត្រា ១.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីក្រមការ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងផែនការ ដូចមានរាយនាមខាងក្រោម ៖

១	ឌុច ដេង	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
២	សាន សុខុមាល	ស្រី	នាយក្រមការ	ថ្នាក់លេខ ១
៣	ប៉ិច សារី	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
៤	ឥន្ទ សារ៉ិន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
៥	ជិន សាផុន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
៦	សេង ឡាយ	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
៧	ផល បុណ្យ	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
៨	ឌុច ស៊ាងហ៊ត	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
៩	ស៊ុន ហ៊ិន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
១០	ម៉ៅ សុផុន	ស្រី	នាយក្រមការ	ថ្នាក់លេខ ១
១១	ស៊ុម ឡាយ	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
១២	ម៉ៅ ជន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ១
១៣	ពៅ សេដ្ឋា	ប្រុស	នាយក្រមការ	ថ្នាក់លេខ ២
១៤	រស់ ស៊ីនួន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ២
១៥	ឆេព ស៊ីនួន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ២
១៦	ឈិន ណារី	ស្រី	នាយក្រមការ	ថ្នាក់លេខ ២
១៧	ចិញ សក្តា	ប្រុស	នាយក្រមការ	ថ្នាក់លេខ ២
១៨	សារិត មករា	ប្រុស	នាយក្រមការ	ថ្នាក់លេខ ២
១៩	ចាន់ នីប៉ូល	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២០	នុយ ណារ៉េត	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២១	នារ ត្រី	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២២	ហួត រ័ត្នមុនី	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២៣	ប៊ុន ដារ៉ា	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២៤	មាស នី	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២៥	នាង សារឿន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២៦	អ៊ុក អ៊ាម	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២៧	កែម ចិបុល	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២៨	យឹម រ័ត្ន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៣
២៩	កាំង លាងអ៊ី	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៣០	ទេព្យ ស៊ីណា	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤

៣១	នួន ណាង	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៣២	ឡុច ចំរើន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៣៣	ខុន ធាវី	ស្រី	នាយក្រមការ	ថ្នាក់លេខ ៤
៣៤	ជី ស្មើ	ស្រី	នាយក្រមការ	ថ្នាក់លេខ ៤
៣៥	ឡុង ចរិយសេដ	ស្រី	នាយក្រមការ	ថ្នាក់លេខ ៤
៣៦	លឹម ស្មើ	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៣៧	ប៉េង គៀនសាយ	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៣៨	យឹម អៀន	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៣៩	ស៊ុម ឃី	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៤០	ឈុក សំគីស	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៤
៤១	ស៊ុន ធារី	ស្រី	នាយក្រមការ	ថ្នាក់លេខ ៤
៤២	នី ទុស្សី	ស្រី	នាយក្រមការ	ថ្នាក់លេខ ៥
៤៣	សុក កុសល	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៥
៤៤	ឈុន សុខលីម	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៥
៤៥	ហ៊ុន វណ្ណារ៉ា	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៥
៤៦	ឈុប សុជាតា	ប្រុស	នាយក្រមការ	ថ្នាក់លេខ ៥
	3215.90.10	- - ដុំការបោនសំរាប់ក្រដាសកាបោន	- - Carbon mass for one time carbon paper	kg	7	0	10	0	
	3215.90.60	- - ទឹកខ្មៅសម្រាប់គូររូប និងទឹកខ្មៅសម្រាប់សរសេរ	- - Drawing ink and writing ink	kg	7	0	10	0	
	3215.90.90	- ផ្សេងទៀត	- - Other	kg	7	0	10	0	

ជំពូកទី ៣៣

ប្រេងចម្រាញ់ និងជាតិជ័រឈើឆាំងក្រអូប ផលិតផលជាគ្រឿងក្រអូបឬគ្រឿងសំអាងឆាំងក្រអូប និងផលិតផលសំរាប់ថែរក្សាមុខមាត់រាងកាយ និងសក់

Chapter 33

Essential oils and resinoids; perfumery, cosmetic or toilet preparations

កំណត់សំគាល់

1- ជំពូកនេះមិនរាប់បញ្ចូលនូវ ៖

(a) ជ័រធម្មជាតិឬសារធាតុចំរាញ់ពីរុក្ខជាតិនៃទីតាំងលេខ ១៣.០១ ឬ ១៣.០២ ។

(b) សាប៊ូ និងផលិតផលផ្សេងទៀតក្នុងទីតាំងលេខ ៣៤.០១ ។

(c) ជាតិតេរ៉េបង់ទីនឈើស្រល់ ឬជាតិក្រដាសមានស៊ុលហ្វាត និងផលិតផលផ្សេងទៀតនៅក្នុងទីតាំងលេខ ៣៨.០៥ ។

2- ពាក្យថា "សារធាតុក្រអូប" ក្នុងទីតាំងលេខ ៣៣.០២ មានតែចំពោះសារធាតុនៃទីតាំងលេខ ៣៣.០១ ។ សមាសធាតុក្រអូបដែលបំបែកចេញបន្តពីនោះ ឬសារធាតុសិប្បនិម្មិត

3- ទីតាំងលេខ ៣៣.០៣ ដល់ ៣៣.០៧ អនុវត្តចំពោះផលិតផលជាល្បាយ ឬមិនមែនជាល្បាយ (ក្រៅពីទឹកបិតដែលអប់ក្លិន និងស្លុយស្យុងមានទឹកលាយជាមួយប្រេងចំរាញ់) ដែលប្រើប្រាស់ក្នុងទីតាំងនេះ និងវេចខ្ចប់សំរាប់លក់រាយ ។

Notes

1- This chapter does not cover:

(a) Natural oleoresins or vegetable extracts of heading No. 13.01 or 13.02;

(b) Soap or other products of heading No. 34.01; or

(c) Gum, wood or sulphate turpentine or other products of heading No. 38.05.

2- The expression "odoriferous substances" in heading No. 33.02 refers only to the substances of heading No. 33.01, to odoriferous constituents isolated from those substances or to synthetic aromatics.

3- Heading Nos. 33.03 to 33.07 apply, inter alia, to products, whether or not mixed(other than aqueous distillates and aqueous solutions of essential oils), suitable for use as goods of these headings and put up in packings of a kind sold by retail for such use.

4- ពាក្យថាផលិតផល "គន្ធរស សំរាប់សំអាង ឬសំរាប់តុបតែងខ្លួន" ក្នុងទីតាំង លេខ ៣៣.០៧ គឺបណ្តាផលិតផល កញ្ចប់តូចៗ ដែលមានបំណែកក្លិនក្រអូប ផលិតផលដែលមានក្លិនក្រអូប ដោយសារចំហេះ ក្រដាស និងក្រដាស ដែលបានជ្រលក់ ឬលាបល្អាប ... សំរាប់កែវភ្នែក ឬសំរាប់ភ្នែកសិប្បនិម្មិត សំឡីកប្បាស ក្រណាត់ហ្វឺត និង មិនត្បាញ ដែលបានជ្រលក់ ឬលាប ឬស្រោប ដោយទឹកអប់ ឬជាប់ម្សៅ មុខគ្រឿងសំអាងសំរាប់សត្វ ។

The expressions "perfumery, cosmetic or toilet preparations" in heading No. 3307 applies, inter alia, to the following products: scented sachets; odoriferous preparations which operate by burning; perfumed papers and paper impregnated or coated with cosmetics; contact lens or artificial eye solutions; wadding, felt and nonwovens, impregnated, coated or covered with perfume or cosmetics; animal toilet preparations.

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp			Exp.	
					CD	ST	VAT	ET	
33.01		ប្រេងចំហាយមានឬគ្មានទែរប៉ែន ដោយរួមទាំងប្រេង ខាប់ ស្អិត ជ័រឈើ សុលុយស្យុងខាប់នៃប្រេងចំហាយក្នុងខ្លាញ់ ប្រេងឥតហើរ ក្រមួន ឬផ្សេងៗទៀត ដែលបានមកពីការ ... ផលិតផលរង ទែរប៉ែន ដែលមានជាតិទែរប៉ែនដែលនៅសល់ពីការចំហាយប្រេង ទឹកបិទ ក្លិន និង សុលុយស្យុងមានទឹកលាយជាមួយប្រេង ចំហាយ "ប្រេង ខ្លឹមតែ ..." ។	**Essential oils (terpeneless or not), including concretes and absolutes; resinoids;extracted oleoresins ;concentrates of essential oils in fats, in fixed oils,or in waxes or the like, obtained by enfleurage or maceration; terpenic by-products of the deterpenation of essential oils; aqueous distillates and aqueous solutions of essential oils.**						
		- ប្រេងចំហាយមកពីផ្លែក្រូចជាតិក្រូចឆ្មារ	- Essential oils of citrus fruit :						
	3301.12.00	- - ក្រូចពោធិសាត់	- - Of orange	kg	35	0	10	0	
	3301.13.00	- - ក្រូចឆ្មារ	- - Of lemon	kg	35	0	10	0	
	3301.19.00	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
		- ប្រេងចំហាយពីរុក្ខជាតិ មិនមែនមកពីផ្លែក្រូចក្រូចឆ្មារ .	- Essential oils other than those of citrus fruit:						
	3301.24.00	- - ជីអង្កាម	- - Of peppermint (Mentha piperita)	kg	35	0	10	0	

	3301.25.90	- - - ដទៃទៀត	- - - Of other mints	kg	35	0	10	0
	3301.29	- - ផ្សេងទៀត	- - Other					
		- - - គីឡាថ្នាក់ឱសថកម្ម	- - - Pharmaceutical grade					
	3301.29.11	- - - - ពីស្លឹកគ្រៃ ស្លឹកគ្រៃស្អំ ផ្កាចន្ទន៍ សំបកឈើចែក ខ្ញី ក្រវាញ ហើយនឹងល្ពៅ ឬផ្សេងៗ	- - - - Of lemon grass, of citronella, nutmeg, cinnamon, ginger, cardamom, fennel or palmarose	kg	35	0	10	0
	3301.29.12	- - - - ពីឈើខ្លឹមចន្ទន៍ក្រស្នា	- - - - Of sandalwood	kg	35	0	10	0
	3301.29.19	- - - - ផ្សេងទៀត	- - - - Other	kg	35	0	10	0
		- - - ផ្សេងទៀត	- - - Other					
	3301.29.91	- - - - ពីស្លឹកគ្រៃ ស្លឹកគ្រៃស្អំ ផ្កាចន្ទន៍ សំបកឈើចែក ខ្ញី ក្រវាញ ហើយនឹងល្ពៅ ឬផ្សេងៗ	- - - - Of lemon grass, of citronella, nutmeg, cinnamon, ginger, cardamom, fennel or palmarose	kg	35	0	10	0
	3301.29.92	- - - - ពីឈើខ្លឹមចន្ទន៍ក្រស្នា	- - - - Of sandalwood	kg	35	0	10	0
	3301.29.99	- - - - ផ្សេងទៀត	- - - - Other	kg	35	0	10	0
	3301.30.00	- ជ័រឈើ	- Resinoids	kg	35	0	10	0
	3301.90	- ផ្សេងទៀត	- Other					
	3301.90.10	- - ទឹកចម្រោះ និង ល្បាយប្រេងក្រអូបសម្រាប់ប្រើក្នុងវេជ្ជសាស្ត្រ	- - Aqueous distillates and solution of essential oils suitable for medicinal use	kg	35	0	10	0
	3301.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0
33.02		ល្បាយវត្ថុធាតុក្រអូប និងល្បាយ (រួមទាំងសូលុយស្យុងអាល់កុល) ដែលមានមូលដ្ឋានលើវត្ថុធាតុទាំងនេះមួយ ឬច្រើន ប្រភេទដែលប្រើជាវត្ថុធាតុដើមក្នុងឧស្សាហកម្ម ។	**Mixtures of odoriferous substances and mixtures (including alcoholic solutions) with a basis of one or more of these substances, of a kind used as raw materials in industry; other preparations based on odoriferous substances, of a kind used for the manufacture of beverages.**					
	3302.10	- ប្រភេទដែលប្រើក្នុងឧស្សាហកម្មម្ហូបអាហារ ឬភេសជ្ជៈ	- Of a kind used in the food or drink industries					
	3302.10.10	- - ផលិតផលអាល់កុលក្រអូបប្រភេទប្រើសម្រាប់ផលិតភេសជ្ជៈអាល់កុល ជាទម្រង់រាវ	- - Odoriferous alcoholic preparations of a kind used for the manufacture of alcoholic beverages, in liquid form	kg	7	0	10	0

	3302.10.20	- - វត្ថុធាតុដើមប្រើប្រាស់សំរាប់ផលិតភេសជ្ជៈជាតិស្រាមានសណ្ឋានដទៃទៀត	- - Odoriferous alcoholic preparations of a kind used for the manufacture of alcoholic beverages, in other form	kg	7	0	10	0	
	3302.10.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	3302.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	
33.03	3303.00.00	ទឹកអប់ និងទឹកក្រអូបសំរាប់សំអាង	**Perfumes and toilet waters.**	kg	7	15	10	0	
33.04		ផលិតផលសំរាប់សម្ផស្ស ឬសំរាប់លាបមុខ ដើម្បីថែរក្សា ឬថែទាំស្បែក (ក្រៅពីឱសថ) រួមទាំងផលិតផលការពារពន្លឺថ្ងៃនិងលាបដើម្បីឲ្យស្បែកឡើងស្រអែម ផលិតផលសំរាប់ថែរក្សា លាបដៃ ក្រចកដៃ និងក្រចកជើង ។	**Beauty or make-up preparations and preparations for the care of the skin (other than medicaments), including sunscreen or sun tan preparations; manicure or pedicure preparations.**						
	3304.10.00	- វត្ថុធាតុសំរាប់សំអាងបបូរមាត់	- Lip make-up preparations	kg	35	10	10	0	
	3304.20.00	- វត្ថុធាតុសំរាប់សំអាងភ្នែក	- Eye make-up preparations	kg	35	10	10	0	
	3304.30.00	- វត្ថុធាតុសំរាប់សំអាងក្រចកដៃ ក្រចកជើង	- Manicure or pedicure preparations	kg	35	10	10	0	
		- ផ្សេងទៀត :	- Other						
	3304.91.00	- - ម្សៅ ទោះសង្កត់ឬអត់ក៏ដោយ	- - Powders, whether or not compressed	kg	35	10	10	0	
	3304.99	- - ផ្សេងទៀត :	- - Other .						
	3304.99.10	- - - ក្រែម និងទឹកអប់សំរាប់លាបមុខ និងស្បែក	- - - Face and skin creams and lotions	kg	35	10	10	0	
	3304.99.20	- - - ក្រែមការពារមុន	- - - Anti-acne creams	kg	35	10	10	0	
	3304.99.90	- - - ផ្សេងទៀត	- - - Other	kg	35	10	10	0	
33.05		ថ្នាំលាបសក់	**Preparations for use on the hair.**						
	3305.10.00	- សាប៊ូកក់សក់	- Shampoos	kg	7	0	10	0	
	3305.20.00	- វត្ថុធាតុសំរាប់ធ្វើអោយសក់គ្រើម ឬរួញ	- Preparations for permanent waving or straightening	kg	15	0	10	0	
	3305.30.00	- ថ្នាំបាញ់សក់អោយរឹង និងរលោង	- Hair lacquers	kg	15	0	10	0	

	3305.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	
33.06		ផលិតផលសំរាប់អនាម័យមាត់ ឬធ្មេញ ដោយរួមទាំងម្សៅ និងក្រែមសំរាប់ងាយស្រួលភ្ជាប់ ក្រាសធ្មេញ ។	**Preparations for oral or dental hygiene, including denture fixative pastes and powders; yarn used to clean between the teeth (dental floss), in individual retail packages.**						
	3306.10	- ថ្នាំដុសធ្មេញ :	- Dentifrices :						
	3306.10.10	- - ម្សៅ និងថ្នាំប្រហ៊ីឡាក់ស្ទិក	- - Prophylactic pastes and powders	kg	7	0	10	0	
	3306.10.90	- - ផ្សេងទៀត	- - Other	kg	7	0	10	0	
	3306.20.00	- សរសៃអំបោះប្រើសំរាប់សំអាតចន្លោះធ្មេញ	- Yarn used to clean between the teeth (dental floss)	kg	7	0	10	0	
	3306.90.00	- ផ្សេងទៀត	- Other	kg	7	0	10	0	
33.07		ផលិតផលសំរាប់ប្រើមុនកោរ ពេលកោរ ឬក្រោយពេលកោរ វត្ថុសំរាប់បំបាត់ក្លិនខ្លួនសំរាប់ប្រើពេលមុជទឹក សំរាប់ជំរះរោម បណ្តាផលិតផលក្រអូប ឬផលិតផលសំអាង និងផលិតផលថែរក្សាខ្លួន ដែលមិនបានរៀបរាប់នៅទីតាំងផ្សេងនៃជំពូកនេះបណ្តាវត្ថុសំរាប់បំបាត់ក្លិននៅទីកន្លែង ឬបន្ទប់ទោះជាមិនក្រអូបមាន ឬគ្មានលក្ខណៈរំងាប់មេរោគ ។	**Pre-shave, shaving or after-shave preparations, personal deodorants, bath preparations, depilatories and other perfumery, cosmetic or toilet preparations, not elsewhere specified or included; prepared room deodorisers, whether or not perfumed or having disinfectant properties.**						
	3307.10.00	- វត្ថុសំរាប់ប្រើមុនការកោរ ពេលកោរ និងក្រោយពេលកោរ	- Pre-shave, shaving or after-shave preparations	kg	35	0	10	0	
	3307.20.00	- គ្រឿងក្រអូបផ្ទាល់ខ្លួន និងគ្រឿងបំបាត់ក្លិន	- Personal deodorants and antipersprants	kg	35	0	10	0	
	3307.30.00	- អំបិលក្រអូបសំរាប់បន្ទប់ទឹក និងវត្ថុធាតុផ្សេងទៀតសំរាប់បន្ទប់ទឹក	- Perfumed bath salts and other bath preparations	kg	35	0	10	0	
		- វត្ថុសំរាប់ធ្វើអោយក្រអូប ឬមានក្លិនប្រហើរក្នុងបន្ទប់ទឹក រួមទាំងបន្ទប់ផ្សេងទៀត	- Preparations for perfuming or deodorizing rooms, including odoriferous preparations used during religious rites .						
	3307.41.00	- - "Agarbatti" និងវត្ថុក្រអូបដទៃទៀត ដែលប្រើប្រាស់ដោយដុត	- -"Agarbatti" and other odoriferous preparations which operate by burning	kg	35	0	10	0	
	3307.49	- - ផ្សេងទៀត :	- - Other .						
	3307.49.10	- - - វត្ថុធាតុសំរាប់ធ្វើអោយក្រអូបក្នុងបន្ទប់	- - - Room perfuming preparations	kg	35	0	10	0	

	3307.49.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	3307.90	- ផ្សេងទៀត :	- Other .						
	3307.90.10	- - ផលិតផលងូតទឹកសត្វ គ្រឿងក្រអូប និងគ្រឿងសំអាងផ្សេងៗ រាប់ទាំងថ្នាំជំរុះរោមផង	- - Animal toilet preparations; other perfumery or cosmetics, including depilatories	kg	35	0	10	0	
	3307.90.20	- - ល្បាយសំរាប់កែវប្រើក្នុងភ្នែក	- - Contact lens solution	kg	35	0	10	0	
	3307.90.30	- - ក្រដាស និង ក្រដាសជូតមាត់ ដែលមានក្លិនក្រអូប	- - Paper and tissues, impregnated or coated with perfume or cosmetics	kg	35	0	10	0	
	3307.90.40	- - ទឹកអប់ ឬគ្រឿងសំអាងផ្សេងទៀត រួមទាំងថ្នាំជំរុះរោម	- - Other perfumery or cosmetics, including depilatories	kg	35	0	10	0	
	3307.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	

ជំពូកទី ៣៤

Chapter 34

សាប៊ូ ភាវៈសកម្មសំអាតផ្ទៃខាងក្រៅនៃសរីរាង្គ ផលិតផលសំរាប់បោកលាង ផលិតផលដែលមានជាតិរំអិល ក្រមួនសិប្បនិម្មិត ក្រមួនកែច្នៃរួច ផលិតផលសំរាប់ជូតរំលីង ឬដុសខាត់ ទៀននិងវត្ថុប្រហាក់ប្រហែល ម្សៅសិល្បៈ សូត្របិទ ក្រមួនសំរាប់ពេទ្យធ្មេញ និងគ្រឿងផ្សំនានាសំរាប់ពេទ្យធ្មេញ ដែលមានជាតិម្នាងសិលាជាមូលដ្ឋាន

Soap, organic surface-active agents, washing preparations, lubricating preparations, artificial waxes, prepared waxes, polishing or scouring preparations, candles and similar articles, modelling pastes, and "dental waxes" and dental preparations with a basis of plaster

កំណត់សំគាល់

Notes

1.- ជំពូកនេះមិនរាប់បញ្ចូលនូវ ៖

This Chapter does not cover

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០១ សហវ

លិខិតចូល
ថ្ងៃទី២០ ខែកក្កដា ឆ្នាំ200

សារាចរណែនាំ

ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា ខេត្ត ក្រុងឆ្នាំ ២០០៨

យោងសារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

យោងប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេស នៃការរៀបចំគំរោងថវិកាខេត្ត ក្រុង ឆ្នាំ ២០០៨ ដូចតទៅ ÷ គំរោងថវិកាខេត្ត ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ត្រូវរៀបចំទៅតាមទំរង់ និងមាតិកាថវិកា ដូចមានជូនភ្ជាប់ជាមួយ និងសារាចរណែនាំនេះ ។

I. ការរៀបចំចំណូលថវិកា :

1. ការគិតគូរចំណូលចរន្តរបស់ថវិកាខេត្ត-ក្រុង អាស្រ័យទៅលើប្រភពនៃផលិតផល ឬផលទុន ដូចមានចែងក្នុងមាត្រា ១៧ ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលបានកែប្រែដោយមាត្រា ៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ផ្អែកតាមប្រភពធនធានខាងលើនេះ អភិបាលខេត្ត-ក្រុង ត្រូវរៀបចំនូវគំរោងចំណូលថវិការបស់ខេត្ត-ក្រុង សាមីដូចតទៅ ÷

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  + លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  + ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  + ប៉ាន់ស្មានលើការវិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើង ឬត្រូវពិនិត្យពិចារណាលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
  + ចំណូលដែលសង្ឃឹមថា បានមកពីការបង្កើតពន្ធថ្មី (ករណីមានគោលនយោបាយថ្មី) ។

ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានផលប្រយោជន៍ ដូចជាកិច្ចសន្យាជួល សេវាកម្ម។ល។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិចំណូលពិតនៃឆ្នាំកន្លងមក និងការវិវឌ្ឍន៍នៃសេដ្ឋកិច្ច។

ចំពោះនីតិវិធី គឺអភិបាលខេត្ត-ក្រុង ត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាខាពន្ធដារ និងមន្ទីរជំនាញដែលពាក់ព័ន្ធ ក្នុងការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ សំរាប់ថវិកាខេត្ត-ក្រុង ដើម្បីមកចូលរួមពិភាក្សាគិតគូររៀបចំជាគំរោងចំណូល ទៅតាមជំពូក គណនី អនុគណនីនៃតារាងឧបសម្ព័ន្ធទី១ ដែលជូនភ្ជាប់មកជាមួយនេះ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិកាខេត្ត-ក្រុង ក្នុងករណីដែលមាន ក៏ត្រូវយកចិត្តទុកដាក់រៀបចំអោយមានក្នុងគំរោងចំណូល។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយផ្សេងៗរបស់ ដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត-ក្រុង រួចហើយនោះ។

II. ការរៀបចំចំណាយថវិកា :

3. ខេត្ត-ក្រុង ត្រូវរៀបចំនូវគំរោងចំណាយទៅតាមជំពូក គណនី អនុគណនីនៃការចាត់ថ្នាក់តាមសេដ្ឋកិច្ចទាំងអស់ ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។ ការរៀបរៀងគំរោងត្រូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗអោយច្បាស់លាស់ និងដោយផ្អែកទៅលើកត្តានានា ដែលទាក់ទងផ្ទាល់មកនឹងមុខចំណាយនោះដូចជា តារាងបុគ្គលិក បញ្ជីសារពើភណ្ឌ តំលៃ ចំនួន ប្រភេទ ។ល។ ចំពោះសម្ភារៈបរិក្ខា ដែលប្រើប្រាស់ជាប្រចាំត្រូវគិតគូរដោយផ្អែក តាមតួលេខស្ថិតិគណនេយ្យថវិកាជាក់ស្តែង នៃបណ្តាឆ្នាំកន្លងមក។ ចំណែកឯ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើការកំណត់របស់អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស និង ប្រាក់ឈ្នួលផ្ទះ ទឹកភ្លើងរបស់អភិបាល អភិបាលរងខេត្ត ក្រុង ត្រូវគ្រោងក្នុងការគ្រោងការ គិតអប្បបរមាដោយផ្អែក លើមូលដ្ឋានលទ្ធភាពនៃថវិកាខេត្ត-ក្រុង និងការកំណត់របស់អភិបាលខេត្ត ក្រុង។

គំរោងចំណាយទាំងអស់របស់ថវិកាខេត្ត-ក្រុង ត្រូវបានសរុបនៅក្នុងតារាងឧបសម្ព័ន្ធទី២ ដែលជូនភ្ជាប់មកជាមួយនេះ។

4. ជាទូទៅ សំណើចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញអោយឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវ ហ្មត់ចត់ និងសមហេតុផល។ លិខិតយុត្តិការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា។

II.1. ការរៀបចំគំរោងចំណាយចរន្ត :

5. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ៖

ប្រភេទ ១ : ចន្សោឆាយសេចា
ជំពូក ៦២ និង ៦៤ សេវាខាងក្រៅផ្សេងៗ និងបន្ទុកបុគ្គលិក

៦. ចំណាយសំរាប់បុគ្គលិកត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ចំណាយលើជំពូកនេះ ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគំរោងថវិកា ។ ចំណាយបន្ទុកបុគ្គលិកត្រូវគ្រោងដោយបង្កើន២០ % លើបៀវត្សមូលដ្ឋានទៅតាមតារាងប្រាក់បៀវត្សថ្មី នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៧ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលនិងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនិងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ខេត្ត ក្រុង មិនត្រូវគិតអតិផរណានៅក្នុងចំណាយបៀវត្សនេះទេ ។

ក្នុងករណីដែលខេត្ត-ក្រុង ស្នើសុំបន្ថែមបុគ្គលិកអណ្តែត ភ្នាក់ងារជាប់កិច្ចសន្យា និងបុគ្គលិកប្រភេទ "គ" "ឃ" លើសពីក្របខ័ណ្ឌគណនេយ្យ ដែលបានពិភាក្សារួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវស្នើសុំការធានាចំណាយថវិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតបន្ថែមអោយ ខេត្ត-ក្រុង ជ្រើសរើស និងប្រើប្រាស់ ។

ចំពោះគំរោង ចំណាយអំពីប្រាក់បំណាច់បុគ្គលិកអណ្តែត គំរោងចំណាយអំពីលាភការភ្នាក់ងារជាប់កិច្ចសន្យា និងកន្ទោរមអាទិភាព គឺចាំបាច់ត្រូវតែមានសេចក្តីសំរេចអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្របខ័ណ្ឌគណនេយ្យ ដែលបានពិភាក្សារួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក- បុគ្គលិកដែលកំពុងមានក្នុងពេលបច្ចុប្បន្ន

7. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទខេត្ត-ក្រុង ត្រូវបូកសរុបនៅក្នុងតារាង៥ "ខ" ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលខេត្ត-ក្រុងមាន ។

8. បុគ្គលិក មន្ត្រីរាជការ ដែលស្ថិតនៅតាមអង្គភាពនីមួយៗហើយចំនួន នេះត្រូវតែផ្ទៀងផ្ទាត់ជាមួយ នឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ) ។

៩. ខេត្ត-ក្រុង ត្រូវលំអិតចំនួនបុគ្គលិកទៅតាមស្រុក ខណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

ខ- ការជ្រើសរើសបុគ្គលិកថ្មី

10. អភិបាលខេត្ត-ក្រុង តែងតាំងបុគ្គលិកខេត្ត-ក្រុង ក្នុងក្របខណ្ឌនៃថវិការបស់ខេត្ត-ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋានដោយឡែកដែលមានជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមកាតព្វកិច្ចរបស់មុខងារសាធារណៈទាំងអស់ ។

ជំពូក ៦០ និង ៦១ ការទិញ និងសេវាខាងក្រៅ

11. ជំពូក ៦០ និង ៦១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបានហ្មត់ចត់ និងសន្សំសំចៃ ក្នុងឆ្នាំ ២០០៨ ផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ ។ ឥណទានចំណាយផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិតប្រហាក់ប្រហែល នឹងឆ្នាំ២០០៧ តែប៉ុណ្ណោះ ។

មួយផ្នែកទៀតជាឥណទានសំរាប់បំរើដល់គុណប្រយោជន៍របស់ខេត្ត-ក្រុង ក្នុងការរៀបចំមូលដ្ឋានសំភារៈ នៃសេវាសាធារណៈ និងការអភិវឌ្ឍន៍របស់ខេត្ត-ក្រុង ។ ផ្អែកលើផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង របស់ក្រសួងមហាផ្ទៃ ខេត្ត-ក្រុងនីមួយៗ ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយ អាទិភាពនៃគំរោងចំណាយលំអិតជួសជុល និងកសាងថ្មី អំពីការងារជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សានៃគំរោងថវិកាប្រចាំឆ្នាំ ។

12. ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប ។ ម្យ៉ាងទៀត ខេត្ត-ក្រុងមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសំរាប់ចំណាយទូរស័ព្ទ អគ្គិសនី ទឹក ខេត្ត-ក្រុងត្រូវគ្រោងអោយបានគ្រប់គ្រាន់សំរាប់តំរូវការក្នុងឆ្នាំ និងការសងបំណុល ។ ក្នុងករណីដែលខេត្ត-ក្រុង គ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់ខេត្ត-ក្រុង និងដាក់កម្មវិធីចំណាយសំរាប់ទូទាត់ជូនខេត្ត-ក្រុង ដោយស្វ័យប្រវត្តិ ។

13. ចំពោះឥណទានសំរាប់ចំណាយជាគុណប្រយោជន៍ ខេត្ត ក្រុង ខេត្ត ក្រុងត្រូវគ្រោងឥណទានតាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គីភ័យ ការផ្គត់ផ្គង់ទឹក...) និងតាមការដ្ឋាននីមួយៗ

៩. ខេត្ត-ក្រុង ត្រូវលំអិតចំនួនបុគ្គលិកទៅតាមស្រុក ខណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

ខ- ការជ្រើសរើសបុគ្គលិកថ្មី

10. អភិបាលខេត្ត-ក្រុង តែងតាំងបុគ្គលិកខេត្ត-ក្រុង ក្នុងក្របខណ្ឌនៃថវិការបស់ខេត្ត-ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋានដោយឡែកដែលមានជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤. ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមកាតព្វកិច្ចរបស់មុខងារសាធារណៈទាំងអស់ ។

ជំពូក ៦០ និង ៦១ ការងារ និងសេវាខាងក្រៅ

11. ជំពូក ៦០ និង ៦១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបានហ្មត់ចត់ និងសន្សំសំចៃ ក្នុងឆ្នាំ ២០០៨ ផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ ។ ឥណទានចំណាយផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិតប្រហាក់ប្រហែល នឹងឆ្នាំ២០០៧ តែប៉ុណ្ណោះ ។

មួយផ្នែកទៀតជាឥណទានសំរាប់បំរើដល់គុណប្រយោជន៍របស់ខេត្ត-ក្រុង ក្នុងការរៀបចំមូលដ្ឋានគ្រឹះនៃសេវាសាធារណៈ និងការអភិវឌ្ឍន៍របស់ខេត្ត-ក្រុង ។ ផ្អែកលើផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង របស់ក្រសួងមហាផ្ទៃ ខេត្ត-ក្រុងនីមួយៗ ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយ អាទិភាពនៃគំរោងចំណាយលំអិតជួសជុល និងកសាងថ្មី អំពីការងារជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សានៃគំរោងថវិកាប្រចាំឆ្នាំ ។

12. ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប ។ម្យ៉ាងទៀត ខេត្ត-ក្រុងមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈ ការិយាល័យ ប្រេងឥន្ធនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងយ៉ាងម៉ឹងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសំរាប់ចំណាយទូរស័ព្ទ អគ្គិសនី ទឹក ខេត្ត-ក្រុងត្រូវគ្រោងអោយបានគ្រប់គ្រាន់សំរាប់តំរូវការក្នុងឆ្នាំ និងការសងបំណុល ។ ក្នុងករណីដែលខេត្ត-ក្រុង គ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់ខេត្ត-ក្រុង និងដាក់កម្មវិធីចំណាយសំរាប់ទូទាត់ជូនខេត្ត-ក្រុង ដោយស្វ័យប្រវត្តិ ។

13. ចំពោះឥណទានសំរាប់ចំណាយជាគុណប្រយោជន៍ ខេត្ត ក្រុង ខេត្ត ក្រុងត្រូវគ្រោងឥណទានតាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គីភ័យ ការផ្គត់ផ្គង់ទឹក...) និងតាមការដ្ឋាននីមួយៗ

19. គំរោងវិនិយោគរបស់ខេត្ត ក្រុងដែលអាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងបានទទួលគោលការណ៍អនុញ្ញាត ជាផ្លូវការ អោយគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិកាខេត្ត-ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត-ក្រុងមានអតិរេកចរន្ត ឬ មានចំណូលជាមូលធនផ្ទៃក្នុង ខេត្ត-ក្រុងផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬគំរោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត-ក្រុង ដើម្បីរកគំរោងចូលទៅក្នុងគំរោងថវិការបស់ខេត្ត-ក្រុង។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រាការចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគំរោង ដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

20. ចំណាយនេះ ជាចំណាយកសាងថ្មីដែលមានទំហំទឹកប្រាក់ច្រើន ដូចជា ដីធ្លី អាគារ រៀបចំផ្ទៃអាគារ និងសំណង់ផ្សេងៗទៀត ។

III. សរុបគំរោងចំណូល ចំណាយ :

21. ឆ្នាំ ២០០៨ គឺជាឆ្នាំទី ៣ នៃការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និងជាឆ្នាំទី ៤ នៃការបន្ត អនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តរក្សាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមពី ៦ ទៅ ៧ ភាគរយប្រកបដោយចីរភាព និងបន្តរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុតក្នុងការឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ **ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន** ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំដែលត្រូវបន្តជំរុញការអនុវត្តន៍កម្មវិធីកែទំរង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា ការកែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកំលាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ជាពិសេសគឺជាឆ្នាំដែលត្រូវរៀបចំការបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

គំរោងចំណូល ចំណាយថវិការបស់ខេត្ត-ក្រុងនីមួយៗដែលបានលើកឡើង រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗផង។ គំរោងថវិកាចំណាយនេះ ត្រូវរៀបចំអោយមានតុល្យភាពពិតប្រាកដ ដើម្បីរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ក្នុងឆ្នាំ ២០០៨ នេះគ្រប់ខេត្ត ក្រុងត្រូវគ្រោងចំណាយចរន្តដែលមានលក្ខណៈជាចំណាយរដ្ឋបាលទទួលសាធក្នុងកំរិតប្រហាក់ប្រហែលនឹងថវិកាដែលបានអនុម័តក្នុងឆ្នាំ ២០០៧ ។

22. ចំពោះគំរោងចំណាយចរន្ត ខេត្ត-ក្រុងត្រូវភ្ជាប់មកជាមួយនូវគំរោងបែងចែកលំអិត តាមស្រុកនីមួយៗ និងបណ្តាអង្គភាពចំណុះដែលមានទ្រង់ទ្រាយធំ ។

23. ដោយឡែកនៅឆ្នាំ ២០១៨ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការឈានទៅសម្រេចអោយបាននូវគោលដៅជំហានទី ១ គឺការធានាភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការបន្តជំរុញការកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា ដើម្បីធានាអោយការបើកផ្តល់ថវិកាបានទាន់ពេលវេលា និងការកសាងក្របខ័ណ្ឌគោលនយោបាយចំណូលដើម្បីរក្សាស្ថេរភាព និងនិរន្តរភាពចំណូល ។ មន្ទីមនឹងនេះ បន្តជំរុញការរៀបចំផែនការសកម្មភាព និងបន្តអនុវត្តនូវបណ្តុំសកម្មភាពការងារសំរាប់ត្រៀមឈានទៅជំហានទី ២ និងទី ៣ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការពង្រឹងការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយ ដែលរួមមាន ការបន្តពង្រឹង និងកែលំអរការអនុវត្តន៍ប្លង់គណនេយ្យនិងមាតិកាថវិកាថ្មី ការបន្តពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី និងការបន្តជំរុញការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីអោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មី ដែលបាន និងកំពុងកសាង និងដាក់អោយអនុវត្តដោយផ្នែកៗ និងជាបណ្តើរៗ ក្រោមកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ។

24. បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ពិសេស ធានាពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន និងពង្រឹងមូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីឆ្ពោះទៅរកគោលការណ៍ "រដ្ឋបាលឯកភាព" ដូចមានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងអនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និងការផ្តល់ថវិកាទៅមូលនិធិឃុំ សង្កាត់ រួមមានទាំងពង្រឹងភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តសិក្សាដើម្បីដាក់អោយអនុវត្តសាកល្បងនូវការប្រមូលចំណូលផ្ទាល់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

25. បង្កើនមូលនិធិឃុំ សង្កាត់ ឆ្នាំ ២០១៨ ដល់ ២.៧% នៃចំណូលចរន្តថវិកាជាតិ ២០១៧ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ស្របតាមគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ។

26. ពេលទទួលបានសារាចរណែនាំ ខេត្ត ក្រុង ត្រូវរៀបចំជាបន្ទាន់នូវតារាងចំណូល ចំណាយថវិការបស់ខ្លួនសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ទៅតាមឧបសម្ព័ន្ធតារាងគំរូ (ឧបសម្ព័ន្ធទី ១ ឧបសម្ព័ន្ធទី ២ និងតារាងលេខ ១ ដល់លេខ៧) ដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើរមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន) ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៧ ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ពិភាក្សាកិច្ចការជំនាញ និងបូកសរុបសំរាប់ពិភាក្សាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែ សីហា ឆ្នាំ ២០០៧ ។ តួលេខតារាងចំណូល ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកតាគិតបំផុតគិតត្រឹម ០.١ លានរៀល ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលខេត្ត-ក្រុងទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។/.

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង
  (ដើម្បីមុខការ)
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ឧបសម្ព័ន្ធទី១ ។

ការគ្រប់គ្រងឆ្នាំ ២០០៨

តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

ជំពូក	គណនី	គណនី	ការរាយមុខចំណូល (តាមមាតិកាថវិកា)	ការគ្រប់គ្រងឆ្នាំ ២០០៧			គំរោងឆ្នាំ ២០០៨
				ច្បាប់ដើមឆ្នាំ	អនុវត្តឆមាសទី១	ចាប់ស្មានឆ្នាំ	

ថ្ងៃទី..............ខែ..... ....ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី..............ខែ..............ឆ្នាំ ២០០៧

មន្ត្រីលេខា និង គ្រូប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ.............ឆ្នាំ ២០០៧

មន្ត្រីលេខា និង គ្រូអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ឧបសម្ព័ន្ធទី២

ការគ្រប់គ្រងឆ្នាំ ២០០៨

តារាងសរុបចំណាយថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ការរាយមុខចំណាយ	ការគ្រប់គ្រងឆ្នាំ ២០០៧			គំរោងឆ្នាំ ២០០៨
			(តាមមាតិកាថវិកា)	ច្បាប់ដើមឆ្នាំ	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី........ ....ខែ.......... ..ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី.............ខែ .... ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

គំរោងថវិកាឆ្នាំ ២០០៨

គំរោងចំណាយលើការនិញ (ជំពូក ៦០)

តារាង ១

ឯកតា: លានរៀល

ជំពូក គណនី អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧			គំរោងថវិកាឆ្នាំ ២០០៨		
		មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាមួយឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាមួយឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី ខែ...... . ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី..............ខែ .... ឆ្នាំ ២០០៧

មន្ត្រីលេខា និង ក្រុមប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

មន្ត្រីលេខា និង ក្រុមអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

គំរោងថវិកាឆ្នាំ ២០០៨

គំរោងចំណាយលើសេវាខាងក្រៅ (ជំពូក ៦១) (គុណប្រយោជន៍ខេត្ត ក្រុង)

តារាង ២

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧			គំរោងថវិកាឆ្នាំ ២០០៨		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី.........ខែ.......ឆ្នាំ ២០០៧
អ្នកធ្វើតារាង

ថ្ងៃទី.........ខែ.........ឆ្នាំ ២០០៧
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី..........ខែ...........ឆ្នាំ ២០០៧
បានឃើញ និងឯកភាព
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

គំរោងថវិកាឆ្នាំ ២០០៨

គំរោងចំណាយលើសេវាក្រៅផ្សេងៗ (ជំពូក ៦២)

តារាង ៣

ឯកតា: លានរៀល

ជំពូក គណនី អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមភាពចាំបាច់អាទិភាព)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧			គំរោងថវិកាឆ្នាំ ២០០៨		
		មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី...... ខែ... ...ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី.......... ..ខែ .. .. ឆ្នាំ ២០០៧

មន្ត្រីលេខា និង ប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី...... . ...ខែ ....ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

អភិបាលខេត្ត និង ក្រុងអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

គំរោងថវិកាឆ្នាំ ២០០៨

គំរោងចំណាយលើពន្ធ និង អាករ (ជំពូក ៦៣)

តារាង ៤

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧			គំរោងថវិកាឆ្នាំ ២០០៨		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាទៅឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាទៅឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី .... ខែ...... ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី............ខែ .... ឆ្នាំ ២០០៧

មន្ត្រីលេខា និង ក្រោមប្រធានមន្ត្រី

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី..........ខែ..........ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

មន្ត្រីលេខា និង ក្រោមអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

គម្រោងថវិកាឆ្នាំ ២០០៨

គម្រោងចំណាយលើបន្ទុកបុគ្គលិក (ជំពូក ៦៤)

តារាង៥ "ក"

ឯកតា លានរៀល

ជំពូក គណនី អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧			គម្រោងថវិកាឆ្នាំ ២០០៨		
		មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាលម្អិត)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាលម្អិត)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី...........ខែ............ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី............ខែ ....ឆ្នាំ ២០០៧

មន្ត្រីលេខា និង ក្រោមប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ............ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

មន្ត្រីលេខា និង ក្រោមអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តារាង៥ "ខ"

ខេត្ត ក្រុង:..........

ការគ្រប់គ្រងឆ្នាំ ២០០៧
តារាងសរុបនៃបុគ្គលិក, បៀវត្ស និង ប្រាក់បំណាច់

អង្គភាព	បៀវត្ស សរុប	ចំនួនបុគ្គលិក សរុប	ប្រភេទបុគ្គលិកដែលមានសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧					បុគ្គលិក អណ្តែត	បុគ្គលិក ជាប់កិច្ចសន្យា
			បុគ្គ.អចិន្ត្រៃយ៍សរុប	ប្រភេទ "ក"	ប្រភេទ "ខ"	ប្រភេទ "គ"	ប្រភេទ "ឃ"		
សរុប									
ខុទ្ទកាល័យ									
អង្គភាព									
អង្គភាព									
អង្គភាព									
អង្គភាព									
អង្គភាព									
....									
....									
....									
....									
....									
....									

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧
បានឃើញ និងឯកភាព
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

គំរោងថវិកាឆ្នាំ ២០០៨

គំរោងចំណាយលើឧបត្ថម្ភធន និងជំនួយសង្គម (ជំពូក ៦៥)

តារាង ៦

ឯកតា: លានរៀល

ជំពូក គណនី អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧			គំរោងថវិកាឆ្នាំ ២០០៨		
		មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី ... ... ខែ........... ឆ្នាំ ២០០៧
អ្នកធ្វើតារាង

ថ្ងៃទី ... .ខែ . .. ឆ្នាំ ២០០៧
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ............ឆ្នាំ ២០០៧
បានឃើញ និងឯកភាព
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

គំរោងថវិកាឆ្នាំ ២០០៨

អចលកម្មអរូបី និងអចលកម្មរូបី (ជំពូក ២០ និង ២១)

តារាង ៧

ឯកតា: លានរៀល

ជំពូក គណនី អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧			គំរោងថវិកាឆ្នាំ ២០០៨		
		មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី..... ខែ ..... ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី............ខែ .... ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ...........ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ: ០១.សយ.សរណន/០៧

ទទួលបានមកដល់
ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៧

សារាចរណែនាំ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សូមជម្រាបមក

- លោក លោកស្រី ប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង
- លោក លោកស្រី ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង អមតុលាការខេត្ត-ក្រុង

កម្មវត្ថុ: សារាចរណែនាំស្តីពីចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្តីដែលមានពាក់ព័ន្ធនឹងដីរដ្ឋ ។

យោង : - អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ

- អនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានលើកឡើងក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ" នៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៧

កន្លងមកក្រសួងយុត្តិធម៌បានពិនិត្យឃើញថា តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុង មិនទាន់យកចិត្តទុកដាក់ខ្ពស់ ក្នុងការអនុវត្តភារកិច្ចលើចំណាត់ការ និងដោះស្រាយរឿងក្តីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងភោគៈ ឬកម្មសិទ្ធិលើដី ដែលចាត់ថាជាដីរដ្ឋ ឱ្យបានត្រឹមត្រូវតាមស្មារតីនៃរដ្ឋធម្មនុញ្ញ និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជានៅឡើយ ។ ការសម្រេចដល់អង្គសេចក្តីលើវិវាទដីធ្លី ឬសំណុំរឿងដែលពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិលើដីធ្លី ដោយមិនបានពិនិត្យ និងពិចារណាលើនីត្យានុកូលភាពនៃលិខិតបញ្ជាក់សិទ្ធិ កិច្ចសន្យា ឬឯកសារគតិយុត្ត ពាក់ព័ន្ធនឹងសិទ្ធិលើដីវិវាទ បានបង្កឱ្យមានភាពអវិជ្ជមានកើតឡើង ហើយធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការគ្រប់គ្រង និងសុវត្ថិភាពគតិយុត្តនៃដីធ្លី ជាពិសេសដីរដ្ឋ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ភូមិបាលឆ្នាំ ២០០១ និង អនុក្រឹត្យ លេខ ១១៨ អនក្រ.បក

ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។ ទង្វើនេះ ក៏បានធ្វើឱ្យប៉ះពាល់ដល់កិត្យានុភាពរបស់ប្រព័ន្ធតុលាការ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា លើវិស័យគ្រប់គ្រងដីធ្លី ផងដែរ ។

ដើម្បីធានាសុវត្ថិភាពគតិយុត្តនៃដីរដ្ឋ និងបង្កើនការជឿទុកចិត្តសាធារណៈ ក៏ដូចជាការលើកកំពស់កិត្យានុភាពរបស់ប្រព័ន្ធតុលាការ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងយុត្តិធម៌ សូមធ្វើការណែនាំដល់តុលាការ និងអយ្យការអមតុលាការខេត្ត-ក្រុង ដូចខាងក្រោម :

១- វិវាទនៃសិទ្ធិលើដីធ្លី

នៅពេលទទួលបានបណ្តឹងពាក់ព័ន្ធនឹងវិវាទនៃសិទ្ធិលើដី តុលាការត្រូវពិនិត្យជាបឋមអំពីឯកសារគតិយុត្តដែលបញ្ជាក់សិទ្ធិលើដីវិវាទនោះ ជាអាទិ៍ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដែលត្រូវបានផ្តល់ឱ្យតាមមាត្រា ២៤២ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ហើយត្រូវចាត់ការដូចតទៅ :

ក-ក្នុងករណីដីវិវាទនេះ មានឯកសារគតិយុត្តដូចបានកំណត់ខាងលើនេះ តុលាការអាចបន្តនីតិវិធីនៃបណ្តឹង រហូតដល់ចេញសេចក្តីសម្រេចដល់អង្គសេចក្តី បាន ។

ខ-ក្នុងករណីដីវិវាទនេះ គ្មានឯកសារគតិយុត្តដូចបានកំណត់ក្នុងមាត្រា ២៤២ នៃច្បាប់ភូមិបាលទេ តុលាការត្រូវពិនិត្យជាបឋមអំពីនីត្យានុកូលភាពនៃភោគៈលើដីវិវាទ ដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការបញ្ជាក់អំពីស្ថានភាពគតិយុត្តនៃដីដែលជាកម្មវត្ថុនៃវិវាទ ដើម្បីផ្ទៀងផ្ទាត់ថាតើជាដីរដ្ឋតាមស្មារតី នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ដែរឬទេ។ ក្នុងករណីចាំបាច់ ដើម្បីធានាប្រសិទ្ធិភាព និងសម្រួលដល់ការទទួលព័ត៌មានពាក់ព័ន្ធនឹងដីវិវាទ ពីអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ជាតិពាក់ព័ន្ធ តុលាការត្រូវស្នើសុំមកក្រសួងយុត្តិធម៌ ដើម្បីឱ្យក្រសួងធ្វើការសម្របសម្រួល និង ចាត់វិធានការតាមផ្លូវច្បាប់ ។

កាលបើអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានធ្វើការបញ្ជាក់ជាផ្លូវការថា ដីវិវាទជាដីដែលត្រូវចាត់ជាដីរដ្ឋ តុលាការត្រូវបដិសេធពាក្យបណ្តឹងនោះចោល ។

២- រឿងក្តីដែលមានកម្មវត្ថុពាក់ព័ន្ធនឹងការផ្ទេរ-ប្រគល់សិទ្ធិលើដី

នៅពេលទទួលពាក្យបណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច តាមអានុភាពនៃលិខិតលក់ ឱ្យ ដូរ ឬជំរះមរតក ដូចមានចែងក្នុងមាត្រា ២៤៤ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ឬលិខិតគតិយុត្តផ្សេងៗទៀតនោះ មុននឹងសម្រេចដល់អង្គសេចក្តី តុលាការត្រូវពិនិត្យជាបឋមអំពីសុពលភាព ឬនីត្យានុកូលភាពនៃលិខិតទាំងនេះ ដោយផ្អែកតាមស្មារតីនៃច្បាប់ភូមិបាល (ជាអាទិ៍ ជំពូកទី ៦ និងជំពូកទី ១៨) និងក្រឹត្យ-ច្បាប់លេខ

៣៨ ក្រ.ព ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ជាអាទិ៍ ជំពូកទី ១ និងជំពូកទី ២ ។ តាមផ្លូវច្បាប់ កាលបើលិខិតដែលបញ្ជាក់អំពីទំនាក់ទំនងសិទ្ធិ ឬបង្កើតសិទ្ធិមិនស្របច្បាប់ ការសម្រេចដល់អង្គសេចក្តីអំពីសិទ្ធិ ឬទំនាក់ទំនងសិទ្ធិដែលមានមូលដ្ឋានលើលិខិតទាំងនោះ មិនអាចមានភាពកពិយុត្តបានឡើយ ។

៣-ភារកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងគ្រប់រឿងក្តីទាំងអស់ ដែលមានកម្មវត្ថុពាក់ព័ន្ធនិងដី ដែលអាចចាត់ថាជាដីរដ្ឋ តាមស្មារតីនៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ព្រះរាជអាជ្ញាត្រូវតាំងខ្លួនជាភាគីក្នុងរឿងក្តី ដើម្បីការពារដីរដ្ឋ ដែលជាប្រយោជន៍សាធារណៈ និងសង្គម ។

ក្រសួងយុត្តិធម៌ នឹងចាត់វិធានការយ៉ាងតឹងរ៉ឹងតាមផ្លូវច្បាប់ ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ និងសារាចរណែនាំនេះ ។

ទទួលបានសារាចរណែនាំនេះ តុលាការ និងអយ្យការគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ។

រដ្ឋមន្ត្រី

អង្គ.វង្សវឌ្ឍនៈ

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងនរៀបចំដែនដី នគររូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ